ក្រសួងមហាផ្ទៃ

# សៀវភៅណែនាំ
# ស្ដីពី
# កិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់



អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៧៧០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់

## ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមុខងារ អំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ៤២៧៥ ប្រ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងប្រកាសលេខ៣៨៤០ ប្រ.ក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវ "សៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់"។

**ប្រការ ២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ បុគ្គលិកឃុំ សង្កាត់ មន្ត្រីរាជការដែលមានភារកិច្ចគាំទ្រដល់រដ្ឋបាល ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តដំណើរការនៃកិច្ចការពារកុមារសម្រាប់ ឃុំ សង្កាត់ ត្រូវអនុវត្តតាមគោលការណ៍ បែបបទ និងនីតិវិធីនានាដែលបានកំណត់នៅក្នុងសៀវភៅណែនាំនេះ។

**ប្រការ ៣.-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ច័ន្ទ ៧ កើត..... ខែ...បុស្ស..... ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...២១..... ខែ...ធ្នូ....... ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកិច្ចការនារី
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# អារម្ភកថា

កិច្ចការពារកុមារ គឺជាកាតព្វកិច្ចស្នូលមួយដ៏ចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់តាមវិស័យពាក់ព័ន្ធ ដើម្បីធានាការពារ ពង្រឹង និងលើកកម្ពស់សិទ្ធិកុមារ។ យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋធានាការពារ ការពារសិទ្ធិរបស់កុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។ មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ ទន្ទឹមនេះ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅឆ្នាំ១៩៩២។

ផ្អែកលើមូលដ្ឋានគតិយុត្តខាងលើនេះ ច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព រួមទាំងយន្តការនានា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំដាក់ចេញ ដើម្បីអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា សំដៅធានាដល់កិច្ចការពារកុមារ ការអភិវឌ្ឍកុមារ ការលើកកម្ពស់សិទ្ធិកុមារ និងភាពសុខដុមរមនារបស់កុមារ។ ព្រមជាមួយនេះ កិច្ចការពារកុមារត្រូវបានចូលរួមសហការអនុវត្តយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ រួមមានដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលផងដែរ។

នៅរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ដែលបានបង្កើតនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក.) ដែលបានបង្កើតនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាយន្តការដ៏សំខាន់ក្នុងកិច្ចការពារកុមារនៅថ្នាក់ក្រោមជាតិ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ និងពង្រឹងការអនុវត្តសិទ្ធិកុមារ។ ក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់ គ.ក.ន.ក. និងអ្នកពាក់ព័ន្ធក្នុងការបំពេញតួនាទី ភារកិច្ច ដើម្បីគាំពារកុមារ ក្រសួងមហាផ្ទៃបានដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ រៀបចំឡើងនូវសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់។ សៀវភៅណែនាំនេះរៀបចំឡើងដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្ត ឯកសារបច្ចេកទេស និងបទពិសោធនានានៅមូលដ្ឋានដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ហើយបានដាក់ប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលមួយចំនួនផងដែរ។

សៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់ គឺជាឯកសារតម្រង់ទិស និងផ្តល់នូវចំណេះដឹងជាមូលដ្ឋានដល់ គ.ក.ន.ក. និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តតួនាទី ភារកិច្ចទាក់ទងនឹងកុមារស្របតាមស្ថានភាពជាក់ស្តែងនៃឃុំ សង្កាត់នីមួយៗ។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលមានសមត្ថកិច្ចពាក់ព័ន្ធកិច្ចការពារកុមារ គួរផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ធនធានហិរញ្ញវត្ថុ និងពង្រឹងសមត្ថភាពដល់រដ្ឋបាលឃុំ សង្កាត់ ដើម្បីរដ្ឋបាលឃុំ សង្កាត់ ពិសេស គ.ក.ន.ក. មានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការការពារ និងអភិវឌ្ឍកុមារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ក្នុងនាមក្រសួងមហាផ្ទៃ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះក្រុមការងារបច្ចេកទេសមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់ ព្រមទាំងសូមថ្លែង

អំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ World Vision International អង្គការ Save the Children International អង្គការ Child Fund Cambodia អង្គការ Plan International អង្គការ WOMEN និងអង្គការ UNICEF ដែលបានរួមចំណែកក្នុងការផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស និងថវិកាសម្រាប់រៀបចំសៀវភៅណែនាំនេះ។

ក្រសួងមហាផ្ទៃ សូមស្វាគមន៍រាល់ព័ត៌មានត្រឡប់ ឬមតិយោបល់កែលម្អពីបណ្តាអ្នកអនុវត្តផ្ទាល់ និងអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើឱ្យសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់កាន់តែមានភាពប្រសើរឡើង។ ៚

ថ្ងៃចន្ទ ៧ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


សេចក្តីផ្តើម ........ ១

ជំពូកទី១ ៖ អំពើហិង្សាលើកុមារ និងកិច្ចការពារកុមារ ........ ២

១. និយមន័យកុមារ ........ ២

២. គោលការណ៍នៃការអនុវត្តសិទ្ធិកុមារ ........ ២

៣. កាតព្វកិច្ចរបស់រដ្ឋក្នុងកិច្ចការពារកុមារ ........ ២

៤. ទម្រង់នៃអំពើហិង្សាលើកុមារ ........ ៣

៤.១. អំពើហិង្សាផ្លូវកាយ ........ ៣

៤.២. អំពើហិង្សាផ្លូវភេទ ........ ៣

៤.៣. អំពើហិង្សាផ្លូវចិត្ត ........ ៣

៤.៤. ការមិនអើពើ ........ ៣

៥. កិច្ចការពារកុមារ ........ ៣

៦. គោលដៅនៃកិច្ចការពារកុមារ ........ ៣

ជំពូកទី២ ៖ បណ្តាញកិច្ចការពារកុមារនៅឃុំ សង្កាត់ ........ ៥

១. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ........ ៥

២. អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (អ.ក.ន.ក.) ........ ៦

៣. សាលារៀន ........ ៦

៤. ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ........ ៧

៥. មណ្ឌលសុខភាព ........ ៧

៦. ភូមិ ........ ៨

៧. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់ (អ.ទ.ក.) ........ ៩

៧.១. ការជ្រើសរើសអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់ ........ ៩

៧.២. ភារកិច្ចរបស់អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់ ........ ៩

៨. ក្រុមសហគមន៍មូលដ្ឋាន (ក.ស.ម.) ........ ១១

៩. អង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ........ ១១

ជំពូកទី៣ ៖ វិធានការនៃកិច្ចការពារកុមារនៅឃុំ សង្កាត់ ........ ១២

១. ការបង្ការអំពើហិង្សាលើកុមារ ........ ១២

១.១. ការបណ្តុះបណ្តាលសមាជិក គ.ក.ន.ក. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងអ្នកពាក់ព័ន្ធ ១២

១.២. ការពង្រឹងសមត្ថភាពក្រុមសហគមន៍មូលដ្ឋាន ........ ១៣

១.៣. ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងសហគមន៍ ........ ១៤

១.៤. ការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងសហគមន៍ ........ ១៥

២. ការឆ្លើយតបទៅនឹងអំពើហិង្សា ........ ១៦

២.១. វិធីសាស្ត្ររួម ........ ១៦
២.២. ជំហាននៃការដោះស្រាយករណីអំពើហិង្សាលើកុមារ ........ ១៨
៣. ការបញ្ជូនកុមាររងគ្រោះទៅរកសេវា ........ ២១
៤. ការធ្វើសមាហរណកម្មកុមារ ........ ២២
ជំពូកទី៤ ៖ ការដាក់បញ្ចូលកិច្ចការពារកុមារទៅក្នុងផែនការសកម្មភាព និងថវិកាឃុំ សង្កាត់ ........ ២៤
ឧបសម្ព័ន្ធទី១ ៖ សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់ .... ២៥
ឧបសម្ព័ន្ធទី២.ក ៖ ទម្រង់ចុះបញ្ជីករណី ........ ២៨
ឧបសម្ព័ន្ធទី២.ខ ៖ បញ្ជីកត់ត្រាករណី ........ ២៩
ឧបសម្ព័ន្ធទី៣.ក ៖ ទម្រង់បញ្ជូនកុមារ ........ ៣០
ឧបសម្ព័ន្ធទី៣.ខ ៖ ទម្រង់ផ្តល់ព័ត៌មានត្រឡប់ស្តីពីការបញ្ជូនកុមារ ........ ៣១
ឧបសម្ព័ន្ធទី៤ ៖ ទម្រង់ទុកដាក់កុមារ ........ ៣២
ឧបសម្ព័ន្ធទី៥ ៖ បញ្ជីអ្នកពាក់ព័ន្ធកិច្ចការពារកុមារ ........ ៣៤

## សេចក្តីផ្តើម

កិច្ចការពារកុមារ គឺជារបៀបវារៈគោលនយោបាយស្នូលរបស់ប្រជាជាតិទាំងអស់នៅលើពិភពលោក ដែលរដ្ឋនីមួយៗបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងធ្វើការវិនិយោគយ៉ាងច្រើន ដើម្បីធានាបាននូវធនធានមនុស្ស ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់បន្តវេនក្នុងការអភិវឌ្ឍប្រទេសជាតិរបស់ខ្លួន។ ទន្ទឹមនេះ ដោយកំណើនកុមារ និងយុវជននៅកម្ពុជា មានការកើនឡើងខ្ពស់បើប្រៀបធៀបជាមួយប្រទេសមួយចំនួននៅក្នុងតំបន់ និងការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលលើធនធានកុមារ ព្រះរាជាណាចក្រកម្ពុជាបានធ្វើការវិនិយោគយ៉ាងច្រើនលើវិស័យកិច្ចការពារកុមារ និងការអភិវឌ្ឍកុមារ ព្រមទាំងលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធឱ្យធ្វើការយកចិត្តទុកដាក់ខ្ពស់ចំពោះកុមារ ដើម្បីកសាងធនធានកុមារឱ្យក្លាយជាសសរទ្រូងប្រកបដោយគុណភាពសម្រាប់ប្រទេសជាតិនាពេលអនាគត។ ប៉ុន្តែ ដោយសារការយល់ដឹង ការយកចិត្តទុកដាក់ ការគាំទ្រ និងការចូលរួមពីអ្នកពាក់ព័ន្ធ ឪពុកម្តាយ ឬអាណាព្យាបាលលើការងារកុមារនៅមានកម្រិត បានធ្វើឱ្យអំពើហិង្សា និងការរំលោភបំពានកុមារនៅតែជាបញ្ហាប្រឈមដ៏សំខាន់នៅក្នុងសហគមន៍នាពេលបច្ចុប្បន្ន។ ជាក់ស្តែងតាមការសិក្សាបានបង្ហាញថា កុមាររស់នៅ និងធំធាត់នៅក្នុងគ្រួសារ ឬសហគមន៍ដែលមានអំពើហិង្សា ពួកគេក៏នឹងអាចក្លាយទៅជាអ្នកប្រព្រឹត្តអំពើហិង្សា ឬអាចក្លាយជាជនរងគ្រោះនៃអំពើហិង្សា ឬការរំលោភបំពាន។ ផ្អែកតាមការវាយតម្លៃអំពីបទពិសោធក្នុងការបំពេញតួនាទី និងមុខងាររបស់ គ.ក.ន.ក. បានបង្ហាញថា គ.ក.ន.ក. ជាតួអង្គយ៉ាងសកម្មក្នុងការចូលរួមសម្របសម្រួល និងសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលនានាក្នុងការផ្តល់សេវាកិច្ចការពារកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់បានយ៉ាងមានប្រសិទ្ធភាព។

ហេតុនេះ ដើម្បីរួមចំណែកក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកុមារ និងពង្រឹងអភិវឌ្ឍសមត្ថភាពរបស់ គ.ក.ន.ក. និងអ្នកពាក់ព័ន្ធក្នុងកិច្ចការពារកុមារ ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ រៀបចំសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់នេះឡើង ដែលជាមូលដ្ឋានសម្រាប់ គ.ក.ន.ក. និងអ្នកពាក់ព័ន្ធនានា ប្រើប្រាស់ក្នុងការលើកកម្ពស់សិទ្ធិកុមារ និងកិច្ចគាំពារកុមារ សំដៅរួមចំណែកបង្ការ ទប់ស្កាត់មិនឱ្យកុមារត្រូវបានគេផាត់ចេញពីសង្គម។

សៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់ មាន៤ជំពូក៖

**ជំពូកទី១ ៖ អំពើហិង្សាលើកុមារ និងកិច្ចការពារកុមារ**

បរិយាយអំពីនិយមន័យអំពើហិង្សាលើកុមារ ទម្រង់នៃអំពើហិង្សាលើកុមារ កិច្ចការពារកុមារ គោលដៅនៃកិច្ចការពារកុមារ និងគោលការណ៍ជាសកលក្នុងកិច្ចការពារកុមារ។

**ជំពូកទី២ ៖ បណ្តាញកិច្ចការពារកុមារនៅឃុំ សង្កាត់**

រៀបរាប់អំពីអ្នកពាក់ព័ន្ធនៃបណ្តាញកិច្ចការពារកុមារនៅថ្នាក់មូលដ្ឋាន។

**ជំពូកទី៣ ៖ វិធានការនៃកិច្ចការពារកុមារនៅឃុំ សង្កាត់**

បង្ហាញអំពីការបង្ការអំពើហិង្សាលើកុមារ ការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ការបញ្ជូនកុមាររងគ្រោះទៅរកសេវា និងការធ្វើសមាហរណកម្មកុមារ។

**ជំពូកទី៤ ៖ ការដាក់បញ្ចូលកិច្ចការពារកុមារទៅក្នុងផែនការសកម្មភាព និងថវិកាឃុំ សង្កាត់**

បរិយាយអំពីការដាក់បញ្ចូលសកម្មភាពកិច្ចការពារកុមារទៅក្នុងផែនការសកម្មភាព និងថវិកាសេវាសង្គមប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់។

# ជំពូកទី១

# អំពើហិង្សាលើកុមារ និងកិច្ចការពារកុមារ

រដ្ឋបាលឃុំ សង្កាត់ ជាពិសេសគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) អង្គភាព និងអ្នកពាក់ព័ន្ធ ត្រូវសិក្សាស្វែងយល់ និងមានចំណេះដឹងមូលដ្ឋានក្នុងកិច្ចការពារកុមារដូចខាងក្រោម៖

## ១. និយមន័យកុមារ

កុមារ គឺជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ*(មាត្រា១នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ)*។

## ២. គោលការណ៍នៃការអនុវត្តសិទ្ធិកុមារ

ផ្អែកតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ កុមារគ្រប់រូបត្រូវធានាបានសិទ្ធិជាមូលដ្ឋានដូចខាងក្រោម៖

- ***ឧត្តមប្រយោជន៍របស់កុមារ៖*** ត្រូវតែជាកត្តាចម្បងក្នុងការសម្រេចចិត្តណាមួយ ដែលអាចមានឥទ្ធិពលទៅលើកុមារ មានន័យថា មនុស្សពេញវ័យគ្រប់រូបត្រូវធ្វើអ្វីដែលផ្តល់ឧត្តមប្រយោជន៍ដល់កុមារ។ នៅពេលធ្វើការសម្រេចចិត្តណាមួយ មនុស្សពេញវ័យត្រូវពិចារណា ថាតើការសម្រេចចិត្តរបស់ពួកគេនឹងមានឥទ្ធិពលទៅលើកុមារបែបណាខ្លះ។
- ***ការមិនរើសអើង៖*** មិនត្រូវរើសអើងចំពោះកុមារដោយសារតែស្ថានភាពគ្រួសារ ភាពក្រីក្រ ភេទ អាយុ ពូជសាសន៍ វប្បធម៌ ពណ៌សម្បុរ ភាសា សាសនា សមត្ថភាព រូបរាងកាយ ពិការភាព ឬទស្សនៈនយោបាយឡើយ។
- ***ការរស់រាននិងការអភិវឌ្ឍ៖*** កុមារគ្រប់រូបមានសិទ្ធិពីកំណើតក្នុងការរស់រានមានជីវិត ដែលជាសិទ្ធិមិនអាចដកហូតបាន និងការអភិវឌ្ឍ ឬការលូតលាស់រាងកាយ និងបញ្ញាស្មារតីប្រកបដោយសុខភាពល្អ។
- ***ការគោរពទស្សនៈរបស់កុមារ៖*** កុមារគ្រប់រូប គួរត្រូវបានពិគ្រោះយោបល់ និងចូលរួមក្នុងការសម្រេចចិត្តនានា ដែលមានឥទ្ធិពលលើជីវិតរបស់ពួកគេ។ ការចូលរួមរបស់កុមារក្នុងការសម្រេចចិត្តនេះ ត្រូវធ្វើឡើងស្របទៅតាមកម្រិតនៃការលូតលាស់ និងសមត្ថភាពរបស់កុមារ។
- ***ការរក្សាការសម្ងាត់របស់កុមារ៖*** ត្រូវរក្សាការសម្ងាត់របស់កុមារដែលពាក់ព័ន្ធនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាព ការប្រព្រឹត្តបទល្មើស កិត្តិយស សេចក្តីថ្លៃថ្នូរ សុវត្ថិភាព និងអារម្មណ៍របស់កុមារ។ ការទម្លាយការសម្ងាត់អាចគំរាមកំហែងដល់សុវត្ថិភាព ឬអាយុជីវិតរបស់កុមារ និងក្រុមគ្រួសារ។

## ៣. កាតព្វកិច្ចរបស់រដ្ឋក្នុងកិច្ចការពារកុមារ

រដ្ឋភាគីត្រូវចាត់វិធានការសមស្របខាងនីតិប្បញ្ញត្តិ រដ្ឋបាល សង្គមកិច្ច និងខាងអប់រំ ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា ការធ្វើឱ្យរបួស ឬការរំលោភបំពានលើរាងកាយ ឬលើផ្លូវចិត្ត ការទុកចោលមិនយកចិត្តទុកដាក់ ឬការមិនអើពើ ការធ្វើបាប ឬការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានផ្លូវភេទ ក្នុងអំឡុងពេលដែលកុមារស្ថិតក្រោមការថែរក្សារបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលផ្សេងទៀតដែលមានភារៈថែទាំកុមារ *(មាត្រា១៩នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ)*។

### ៤. ទម្រង់នៃអំពើហិង្សាលើកុមារ

## ៤.១. អំពើហិង្សាផ្លូវកាយ

អំពើហិង្សាផ្លូវកាយ គឺជាការបង្កគ្រោះថ្នាក់ដល់រាងកាយកុមារដោយចេតនាពីអ្នកដទៃ (រួមទាំងសមាជិកគ្រួសារ) ដែលអាចត្រូវបានគេហៅថា ទណ្ឌកម្មលើរូបរាងកាយ ដូចជាការវាយតប់ អង្រួនឱ្យកុមារភិតភ័យ ការចាប់គ្រវាត់ ការដុតឬធ្វើឱ្យរលាក ការពន្លង់ទឹកឬការធ្វើឱ្យថប់ដង្ហើម ការបង្កគ្រោះថ្នាក់ផ្សេងៗទៀត រួមមានការបង្ខំឱ្យកុមារលុតជង្គង់ ឬឈររយៈពេលយូរ ឬសកម្មភាពហិង្សាដទៃទៀតទៅលើរាងកាយ។

## ៤.២. អំពើហិង្សាផ្លូវភេទ

អំពើហិង្សាផ្លូវភេទ គឺជាការបង្ខំ ឬល្បួងកុមារឱ្យរួមភេទ ទោះបីជាកុមារនោះមានការយល់ដឹង ឬមិនយល់ដឹងពីអ្វីដែលបានកើតឡើង ឬកុមារនោះយល់ព្រមក៏ដោយ។ ទង្វើទាំងនេះអាចប៉ះពាល់ដល់រូបរាងកាយ ដូចជាការបៀតបៀនកេរខ្មាស និងការរំលោភបំពានផ្លូវភេទ។ វាក៏អាចជាសកម្មភាពដែលមិនប៉ះពាល់ដល់រាងកាយរបស់កុមារ ដូចជាការឱ្យកុមារមើលខ្សែវីដេអូ ឬរូបភាពអាសអាភាស រួមទាំងសម្ភារអេឡិចត្រូនិកដែលបង្ហាញពីរូបរាងអាក្រាតដែលធ្វើឱ្យរំភើប ឬរំជួលដល់ផ្លូវភេទ។

## ៤.៣. អំពើហិង្សាផ្លូវចិត្ត

អំពើហិង្សាផ្លូវចិត្ត គឺជាការធ្វើបាបផ្លូវអារម្មណ៍របស់កុមារដែលនាំឱ្យកុមារមានផលប៉ះពាល់ធ្ងន់ធ្ងរ និងយូរអង្វែងទៅលើការអភិវឌ្ឍផ្លូវអារម្មណ៍របស់កុមារ។ ទង្វើទាំងនេះ ដូចជាការបង្ហាញប្រាប់កុមារថាពួកគេគ្មានតម្លៃ និងគ្មានអ្នកណាស្រឡាញ់ចូលចិត្ត គ្មានសមត្ថភាពគ្រប់គ្រាន់ ឬមានតម្លៃគ្រប់គ្រាន់ដូចដែលបុគ្គលណាម្នាក់ត្រូវការនោះទេ ឬបណ្ដាលឱ្យកុមារមានអារម្មណ៍ភ័យខ្លាច។

## ៤.៤. ការមិនអើពើ

ការមិនអើពើ គឺជាការមិនយកចិត្តទុកដាក់ចំពោះការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងជាមូលដ្ឋានរបស់កុមារដែលអាចនាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍរបស់កុមារ។

### ៥. កិច្ចការពារកុមារ

កិច្ចការពារកុមារ គឺជាសកម្មភាព និងវិធានការ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាគ្រប់ទម្រង់ (ផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ និងការមិនអើពើ) ការបំបែកកុមារចេញពីគ្រួសារដោយភាពមិនចាំបាច់ អាពាហ៍ពិពាហ៍វ័យកុមារ ការមានផ្ទៃពោះវ័យជំទង់ កុមារទំនាស់នឹងច្បាប់ និងការកេងប្រវ័ញ្ចគ្រប់រូបភាព រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ សំដៅលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ។

### ៦. គោលដៅនៃកិច្ចការពារកុមារ

កិច្ចការពារកុមារមានគោលដៅដូចខាងក្រោម៖

- ធានាឱ្យកុមារមានសុវត្ថិភាពនៅក្នុងសហគមន៍ ដូចជាកន្លែងដែលពួកគេរស់នៅ កន្លែងរៀនសូត្រ និងកន្លែងកំសាន្ត។ល។
- លើកកម្ពស់សមត្ថភាពកុមារ និងអនុញ្ញាតកុមារឱ្យបានចូលរួមក្នុងសកម្មភាពកិច្ចការពារកុមារ



៤

- កុមារទទួលបានសេវាដែលមានលក្ខណៈកុមារមេត្រី (ការប្រើប្រាស់ភាសា និងអាកប្បកិរិយាដែលកុមារអាចយល់បាន និងផ្តល់ឱ្យកុមារនូវសុវត្ថិភាព សន្តិសុខ ទំនុកចិត្ត សិទ្ធិ និងតម្រូវការជាមូលដ្ឋាន)
- កុមារទទួលបានឯកសារគតិយុត្តនានាស្របតាមច្បាប់ (សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត អត្តសញ្ញាណប័ណ្ណ។ល។)
- កុមារដែលមានតម្រូវការពិសេស (កុមារដែលងាយរងគ្រោះ) ដូចជាកុមារកំព្រា កុមារដែលគេបោះបង់ចោល កុមារមានពិការភាព កុមារដែលត្រូវបានរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាព កុមារជាជនជាតិដើមភាគតិច ទទួលបានការជួយគាំទ្រ
- កុមារទទួលបានដំណោះស្រាយត្រឹមត្រូវដូចជាតម្រូវការផ្នែកច្បាប់ និងសេវាសង្គមដោយគោរពគោលការណ៍រក្សាឧត្តមប្រយោជន៍របស់កុមារ។

# ជំពូកទី២

## បណ្ដាញកិច្ចការពារកុមារនៅឃុំ សង្កាត់

ដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្ការ និងឆ្លើយតបទៅនឹងអំពើហិង្សា និងការរំលោភបំពានលើកុមារ រដ្ឋបាលឃុំ សង្កាត់ត្រូវបានលើកទឹកចិត្តក្នុងការពង្រឹង និងពង្រីកកិច្ចការពារកុមារដោយប្រើប្រាស់យន្តការ និងធនធានដែលមានស្រាប់ រួមទាំងការស្នើសុំការជួយគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានពីក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងកុមារ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ នៅរដ្ឋបាលឃុំ សង្កាត់ គ.ក.ន.ក. គឺជាយន្តការផ្លូវការដែលជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ក្នុងកិច្ចការពារកុមារ។ មេឃុំ ចៅសង្កាត់អាចបង្កើតយន្តការផ្សេងទៀតតាមលទ្ធភាពជាក់ស្តែង ដើម្បីឱ្យកិច្ចការពារកុមារកាន់តែមានប្រសិទ្ធភាពស្របតាមការចាំបាច់ ដូចជាអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងក្រុមសហគមន៍មូលដ្ឋានជាដើម។ ព្រមជាមួយនេះ ដើម្បីធានាឱ្យមានការចូលរួមជួយគាំពារ ថែទាំ និងអភិវឌ្ឍកុមារ គ.ក.ន.ក. ត្រូវសហការ ជំរុញ និងលើកទឹកចិត្តដល់អង្គភាពពាក់ព័ន្ធជាអាទិ៍សាលារៀន ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព ភូមិ សហគមន៍ និងអង្គភាពនានាឱ្យគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារជាចម្បងនៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។

### ១. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.)

ផ្អែកតាមប្រកាសលេខ៣៨៤០ប្រក ចុះថ្ងៃអង្គារ ០៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ សមាសភាព និងតួនាទី ភារកិច្ចរបស់ គ.ក.ន.ក. ត្រូវបានកែសម្រួលឡើងវិញ ដើម្បី គ.ក.ន.ក. ធ្វើការផ្តល់យោបល់ និងជួយរដ្ឋបាលឃុំ សង្កាត់ក្នុងការសម្របសម្រួល និងការអនុវត្តសកម្មភាពសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់ ដែលក្នុងនោះរួមទាំងកិច្ចការពារកុមារ។

គ.ក.ន.ក. មានភារកិច្ចក្នុងកិច្ចការពារកុមារដូចខាងក្រោម៖

- កំណត់ និងស្រង់ទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពាននានាលើកុមារ
- សម្របសម្រួលបញ្ជូនកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាននានាទៅទទួលសេវាសមស្រប និងសេវាឯកទេស (ចិត្តសង្គម សុខភាព ផ្លូវច្បាប់...)
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងទិវាកុមារអន្តរជាតិ ថ្ងៃទី០១ ខែមិថុនា
- ចូលរួមអនុវត្តវិធានការសមស្របនានា ដោយផ្អែកលើគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ ដើម្បីអភិវឌ្ឍ និងជួយដល់កុមាររងគ្រោះ រហូតដល់កុមាររងគ្រោះទាំងនេះអាចរស់នៅបានប្រកបដោយសុវត្ថិភាព ព្រមទាំងទទួលបានការអប់រំមូលដ្ឋាន៩ឆ្នាំយ៉ាងតិច និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ជំនាញនានាសម្រាប់ការបំពេញការងារ។

ទន្ទឹមនេះ គ.ក.ន.ក. ត្រូវយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យលទ្ធភាព និងភាពចាំបាច់ក្នុងការបង្កើតអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ
- ចូលរួមអនុវត្តគោលការណ៍ និងគោលនយោបាយកិច្ចការពារកុមារ ដូចជាគោលនយោបាយ

ថែទាំជំនួស គោលនយោបាយស្ដីពីកិច្ចការពារកុមារនៅសាលារៀន គោលនយោបាយកុមារមេត្រី គោលនយោបាយភូមិឃុំមានសុវត្ថិភាព និងគោលនយោបាយផ្ដល់សេវាសង្គមផ្សេងៗដែលមានជាធរមាន

- គាំទ្រកុមារឱ្យចូលរួមក្នុងដំណើរការតាក់តែងគោលនយោបាយ និងការធ្វើសេចក្ដីសម្រេចចិត្តលើកិច្ចការពារកុមារនៅឃុំ សង្កាត់តាមរយៈការអនុវត្តសកម្មភាព និងការធ្វើផែនការសម្រាប់កិច្ចការពារកុមារឃុំ សង្កាត់
- សហការចូលរួមទប់ស្កាត់ រាយការណ៍ ឆ្លើយតប និងចែករំលែកព័ត៌មានរាល់ទម្រង់នៃអំពើហិង្សាលើកុមារដល់អ្នកពាក់ព័ន្ធ
- ចូលរួមអនុវត្តវិធានការកិច្ចការពារកុមារនៅឃុំ សង្កាត់ ដែលរួមមានការបង្ការអំពើហិង្សា និងការរំលោភបំពានលើកុមារ ការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ការបញ្ជូនកុមាររងគ្រោះទៅរកសេវា និងការធ្វើសមាហរណកម្មកុមារ
- សហការចូលរួមជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធផ្ដល់សេវាសង្គមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចផ្ដល់សេវាសង្គម
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់។

**២. អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (អ.ក.ន.ក.)**

ជាគោលការណ៍ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មានភារកិច្ចសម្របសម្រួលការងារប្រចាំថ្ងៃ និងការរៀបចំកិច្ចប្រជុំរបស់ គ.ក.ន.ក.។ ពាក់ព័ន្ធនឹងកិច្ចការពារកុមារ អ.ក.ន.ក. មានភារកិច្ចផ្ដល់យោបល់ សម្របសម្រួល និងជួយដល់ គ.ក.ន.ក. ក្នុងការអនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងកិច្ចការពារកុមារស្របតាមការកំណត់នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពសេវាសង្គម។

ព្រមជាមួយនេះ អ.ក.ន.ក. ត្រូវយកចិត្តទុកដាក់លើភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- សម្របសម្រួលរៀបចំ និងអភិវឌ្ឍន៍សមត្ថភាពដល់អ្នកពាក់ព័ន្ធ (អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ ក្រុមសហគមន៍មូលដ្ឋាន និងក្រុមគោលដៅផ្សេងៗ)
- សម្របសម្រួលក្នុងការចែករំលែកព័ត៌មានពីកិច្ចការពារកុមាររវាងអ្នកពាក់ព័ន្ធនានា
- ចូលរួម និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច អង្គភាព និងឬអ្នកពាក់ព័ន្ធផ្ដល់សេវាសង្គម និងអង្គការដៃគូពាក់ព័ន្ធនានាក្នុងការអនុវត្តវិធានការនៃកិច្ចការពារកុមារនៅឃុំ សង្កាត់
- សម្របសម្រួលការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយលើកិច្ចការពារកុមារដល់អ្នកពាក់ព័ន្ធនៅក្នុងឃុំ សង្កាត់
- បញ្ចូល និងគ្រប់គ្រងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់។

**៣. សាលារៀន**

ស្របតាមគោលនយោបាយស្ដីពីការគាំពារ និងការអភិវឌ្ឍកុមាររបស់ក្រសួងអប់រំ យុវជន និងកីឡា សាលារៀនត្រូវយកចិត្តទុកដាក់លើភារកិច្ចសំខាន់ៗក្នុងកិច្ចការពារកុមារដូចតទៅ៖

- ធានាថាសាលារៀន (សាធារណៈ និងឯកជន) ទាំងអស់នៅក្នុងឃុំ សង្កាត់ ជាកន្លែងដែលមានសុវត្ថិភាព និងមានលក្ខណៈបែបសាលាមេត្រីដល់កុមារគ្រប់រូប ជាពិសេសកុមារមានពិការភាព កុមារកំព្រា កុមារជនជាតិដើមភាគតិច និងកុមារងាយរងគ្រោះ។ល។

- បញ្ជ្រាប និងពង្រឹងតួនាទី និងការទទួលខុសត្រូវលើកិច្ចការពារកុមារទៅក្នុងយន្តការ ឬបណ្ដាញដែលមានស្រាប់ ដូចជាគណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាកុមារ គ្រូទទួលបន្ទុកការពារកុមារ ទីប្រឹក្សាកុមារ អ្នកប្រឹក្សាយោបល់ ហើយបង្កើនកិច្ចសម្របសម្រួលរវាងយន្តការ និងបណ្ដាញទាំងនេះជាមួយ គ.ក.ន.ក. នៅក្នុងឃុំ សង្កាត់
- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តលើកិច្ចការពារកុមារ
- បង្កើនការយល់ដឹងអំពីកិច្ចការពារកុមារដល់បុគ្គលិកអប់រំ សហគមន៍ និងអ្នកពាក់ព័ន្ធ
- បង្កើនកិច្ចសហការរវាងក្រសួង មន្ទីរអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូនានា ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងកិច្ចការពារ និងអភិវឌ្ឍន៍កុមារ
- ចូលរួមអនុវត្តវិធានការនៃកិច្ចការពារកុមារនៅឃុំ សង្កាត់។

នាយក នាយិកាសាលា ឬតំណាងសាលាដែលជាសមាជិក គ.ក.ន.ក. ត្រូវចូលរួមប្រជុំ និងធ្វើរបាយការណ៍ស្ដីពីកិច្ចការពារកុមារជូន គ.ក.ន.ក. ឱ្យបានទៀងទាត់។

### ៤. ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់

ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តតួនាទី ភារកិច្ចដូចដែលមានចែងនៅក្នុងប្រកាសលេខ៧០៥ ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ស្ដីអំពីតួនាទី និងភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់មានភារកិច្ច និងការទទួលខុសត្រូវក្នុងកិច្ចការពារកុមារដូចខាងក្រោម៖

- ចូលរួមផ្សព្វផ្សាយអំពីកិច្ចការពារកុមារ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ
- ប្រមូលទិន្នន័យ និងគ្រប់គ្រងស្ថិតិកុមារតាមភូមិ (ជាពិសេសកុមាររងគ្រោះ និងកុមារងាយរងគ្រោះ) ដើម្បីរៀបចំផែនការបង្ការ ទប់ស្កាត់ និងឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ
- ផ្ដល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ជាពិសេសកុមារ
- សហការជាមួយសមាជិក គ.ក.ន.ក. ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាគ្រប់ទម្រង់ដែលកើតឡើងនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យទាន់ពេលវេលា
- ចូលរួមអនុវត្តវិធានការនៃកិច្ចការពារកុមារឃុំ សង្កាត់។

នាយ ឬនាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ដែលជាសមាជិក គ.ក.ន.ក. ត្រូវចូលរួមប្រជុំ និងធ្វើរបាយការណ៍ស្ដីពីកិច្ចការពារកុមារជូន គ.ក.ន.ក. ឱ្យបានទៀងទាត់។

### ៥. មណ្ឌលសុខភាព

មណ្ឌលសុខភាពមានតួនាទី ភារកិច្ចក្នុងការអនុវត្តតាមសៀវភៅណែនាំស្ដីពីការថែទាំសុខភាពកុមាររងគ្រោះដោយអំពើហិង្សា ឬអំពើរំលោភបំពានផ្លូវភេទដែលដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១៧ ដោយក្រសួងសុខាភិបាល។ មណ្ឌលសុខភាពមានភារកិច្ចសំខាន់ៗក្នុងកិច្ចការពារកុមារ ដូចខាងក្រោម៖

- ចូលរួមអប់រំផ្សព្វផ្សាយអំពីកិច្ចការពារកុមារដល់សហគមន៍
- កំណត់រកកុមាររងគ្រោះដោយអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទ ដែលបានទៅទទួលសេវានៅមណ្ឌលសុខភាពតាមរយៈការសាកសួរ និងពិនិត្យផ្នែកវេជ្ជសាស្ត្រ

- ចុះបញ្ជីកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន ដែលបានបញ្ជូនមកមណ្ឌល-សុខភាព និងរាយការណ៍ជូន គ.ក.ន.ក.
- ផ្តល់សេវាព្យាបាល និងថែទាំសុខភាពតាមការចាំបាច់ដល់កុមាររងគ្រោះដោយរក្សាការសម្ងាត់ និងគោរពឧត្តមប្រយោជន៍របស់កុមារ
- សហការជាមួយ គ.ក.ន.ក. ជាពិសេស អ.ក.ន.ក. ដើម្បីបញ្ជូនកុមាររងគ្រោះទៅរកសេវាសមស្រប
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក. និងអ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពដល់ប្រជាពលរដ្ឋ ជាពិសេសមាតា កុមារ និងទារក
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពអំពីការលើកកម្ពស់សុខភាពដល់ប្រជាពលរដ្ឋ ជាពិសេសមាតា កុមារ និងទារក
- ចូលរួមអនុវត្តវិធានការនៃកិច្ចការពារកុមារនៅឃុំ សង្កាត់។

ប្រធានមណ្ឌលសុខភាព ឬតំណាងដែលជាសមាជិក គ.ក.ន.ក. ត្រូវចូលរួមប្រជុំ និងធ្វើរបាយការណ៍ស្តីពីកិច្ចការពារកុមារជូន គ.ក.ន.ក. ឱ្យបានទៀងទាត់។

**៦. ភូមិ**

ភូមិនីមួយៗនៃរដ្ឋបាលឃុំ សង្កាត់គ្រប់គ្រងដោយមេភូមិ១ (មួយ) រូប និងជំនួយការភូមិ២ (ពីរ) រូប គឺអនុប្រធានភូមិ និងសមាជិកភូមិ។ ផ្អែកតាមសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ និងសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ឆ្នាំ២០១៨ ភូមិមានភារកិច្ច និងការទទួលខុសត្រូវក្នុងកិច្ចការពារកុមារ ដូចខាងក្រោម៖

- គូសផែនទីសេវាសង្គម ដើម្បីកំណត់រកសូចនាករទាក់ទងបញ្ហាកិច្ចការពារកុមារ
- សហការក្នុងការផ្សព្វផ្សាយគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចការបច្ចេកទេសដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន
- ប្រមូលទិន្នន័យ និងទទួលព័ត៌មានពីប្រជាពលរដ្ឋអំពីបញ្ហា និងតម្រូវការរបស់កុមារ ដើម្បីរាយការណ៍ជូន គ.ក.ន.ក. និងអ្នកពាក់ព័ន្ធដែលមានសមត្ថកិច្ច
- ដាក់បញ្ចូលរបៀបវារៈស្តីពីកិច្ចការពារកុមារសម្រាប់កិច្ចប្រជុំរបស់ខ្លួន
- ចូលរួមអនុវត្តវិធានការនៃកិច្ចការពារកុមារនៅឃុំ សង្កាត់
- ចូលរួមការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដានផែនការសកម្មភាព និងថវិការបស់ គ.ក.ន.ក.
- គាំទ្រ សហការ និងសម្របសម្រួលដល់អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងក្រុមសហគមន៍មូលដ្ឋានលើកិច្ចការពារកុមារ ករណីរដ្ឋបាលឃុំ សង្កាត់បានបង្កើតក្រុមទាំងពីរនេះ។

មេភូមិ ឬអនុប្រធានភូមិ ត្រូវចូលរួមប្រជុំ និងធ្វើរបាយការណ៍ស្តីអំពីកិច្ចការពារកុមារជូន គ.ក.ន.ក. ឱ្យបានទៀងទាត់។

**៧. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់ (អ.ទ.ក.)**

ផ្អែកតាមស្ថានភាពជាក់ស្តែង និងលទ្ធភាពរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ មេឃុំ ចៅសង្កាត់ អាចពិចារណាក្នុងការរៀបចំបង្កើតអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារដែលមានពីរផ្នែក គឺផ្នែកអប់រំផ្សព្វផ្សាយ និងផ្នែកផ្តល់សេវាសង្គម។ ផ្នែកនីមួយៗអាចមានសមាជិក១ (មួយ) រូប ឬច្រើនរូប ស្របតាមការចាំបាច់របស់រដ្ឋបាលឃុំ សង្កាត់។

ករណីរដ្ឋបាលឃុំ សង្កាត់សម្រេចបង្កើតអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ រដ្ឋបាលឃុំ សង្កាត់ត្រូវជ្រើសរើសអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារចេញពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឃុំ សង្កាត់សាមី។ អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះ គ.ក.ន.ក.។

## *៧.១. ការជ្រើសរើសអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់*

គ.ក.ន.ក. ត្រូវជ្រើសរើសសមាជិកអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

- ចេះអាន និងចេះសរសេរភាសាខ្មែរ
- មានទីលំនៅច្បាស់លាស់ក្នុងឃុំ សង្កាត់
- ជាបុគ្គលគំរូក្នុងសហគមន៍ (មានការគោរពរាប់អានពីអ្នកភូមិ និងមានទំនាក់ទំនងល្អក្នុងគ្រួសារ និងសហគមន៍ មិនប្រព្រឹត្តអំពើអបាយមុខ មិនញៀនគ្រឿងស្រវឹង មិនប្រើប្រាស់គ្រឿងញៀន និងមិនប្រើអំពើហិង្សា)
- យល់ដឹងអំពីសិទ្ធិកុមារ និងកិច្ចការពារកុមារ ការងារអភិវឌ្ឍន៍សហគមន៍ អភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសង្គមនានា
- យល់ដឹង និងមានបទពិសោធខ្លះៗអំពីរបៀបប្រជុំសហគមន៍
- មានការគាំទ្រពីគ្រួសារ និងសហគមន៍
- មានឆន្ទៈ និងការតាំងចិត្តក្នុងការបម្រើការងារសង្គម។

គ.ក.ន.ក. ត្រូវរៀបចំសំណើសុំគោលការណ៍ទៅមេឃុំ ចៅសង្កាត់ ដើម្បីជ្រើសរើសអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ស្នើក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យជ្រើសរើសអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់។ បន្ទាប់ពីទទួលបានការសម្រេចចិត្តយល់ព្រមពីក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ចេញសេចក្តីសម្រេចតែងតាំងអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ(***ឧបសម្ព័ន្ធទី១***)។

## *៧.២. ភារកិច្ចរបស់អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់*

អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារមានភារកិច្ចដូចតទៅ៖

### *ក. ផ្នែកអប់រំផ្សព្វផ្សាយ*

អ្នកទទួលបន្ទុកអប់រំផ្សព្វផ្សាយមានភារកិច្ចដូចខាងក្រោម៖

- ជួយ អ.ក.ន.ក. ក្នុងការបំពេញតួនាទី ភារកិច្ចក្នុងកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ និងទប់ស្កាត់អំពើហិង្សាលើកុមារតាមរយៈការអប់រំ ផ្សព្វផ្សាយ
- រាយការណ៍ពីករណីអំពើហិង្សាលើកុមារទៅកាន់ អ.ក.ន.ក. ឬអ្នកពាក់ព័ន្ធ ដើម្បីសុំការអន្តរាគមន៍

- ចូលរួមប្រមូលទិន្នន័យកុមាររងគ្រោះ កុមារងាយរងគ្រោះ កុមារងាយនឹងប្រព្រឹត្តបទល្មើស និងកុមារទំនាស់នឹងច្បាប់ដែលត្រូវបានដោះលែង ដើម្បីធ្វើផែនទីសេវាសង្គម និងធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម ដោយសហការជាមួយអាជ្ញាធរភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត
- ចូលរួមធ្វើការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យក្នុងសហគមន៍
- ចូលរួមប្រជុំជាមួយ គ.ក.ន.ក. ដើម្បីចែករំលែកព័ត៌មាន និងផ្ដល់ធាតុចូលសម្រាប់រៀបចំផែនការសកម្មភាព និងថវិកា ដើម្បីអនុវត្តកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- ផ្ដល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមសហគមន៍មូលដ្ឋាន ដែលរួមមានក្រុមមាតាបិតា ក្រុមយុវជន ក្លឹបកុមារ ក្រុមជំនឿសាសនា ។ល។
- ដឹកនាំ និងសម្របសម្រួលពិភាក្សាជាមួយក្រុមសហគមន៍មូលដ្ឋាន ដែលមានការគាំទ្រពី អ.ក.ន.ក. និងអ្នកពាក់ព័ន្ធ ដើម្បីកំណត់ ឬកែសម្រួលភារកិច្ចរបស់ក្រុមសហគមន៍មូលដ្ឋានអំពីកិច្ចការពារកុមារនៅមូលដ្ឋាន
- សហការជាមួយអ្នកផ្ដល់សេវាសង្គម ក្រុមសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអនុវត្តវិធានការនៃកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- ធ្វើរបាយការណ៍ជូន អ.ក.ន.ក. ឱ្យបានទៀងទាត់ស្ដីពីសកម្មភាពកិច្ចការពារកុមារ
- បំពេញកិច្ចការផ្សេងៗទៀតតាមការណែនាំពី គ.ក.ន.ក.។

## ខ. ផ្នែកផ្ដល់សេវាសង្គម

អ្នកទទួលបន្ទុកផ្ដល់សេវាសង្គមមានភារកិច្ចដូចខាងក្រោម៖

- ជួយ អ.ក.ន.ក. ក្នុងការផ្ដល់សេវាគាំទ្រដល់កុមារដែលបានទទួលរងនូវអំពើហិង្សា ដូចជាការឧបត្ថម្ភគាំទ្របំពេញតម្រូវការចាំបាច់បន្ទាន់ និងការផ្ដល់សេវាប្រឹក្សាយោបល់ និងផ្ដល់ព័ត៌មានជាក់លាក់ដល់កុមារ ។ល។
- ចុះបញ្ជីកុមារដែលទទួលរងនូវអំពើហិង្សា ឬដែលតម្រូវឱ្យមានការជួយអន្តរាគមន៍ទាន់ពេលវេលា ផ្អែកតាមជំហាននៃការដោះស្រាយករណី
- តាមដានស្ថានភាពវិវឌ្ឍន៍នៃកិច្ចអន្តរាគមន៍ជួយកុមារដែលរងគ្រោះដោយអំពើហិង្សា និងក្រុមគ្រួសាររបស់ពួកគេ
- រាយការណ៍ពីករណីអំពើហិង្សាលើកុមារទៅកាន់ អ.ក.ន.ក. ដើម្បីសុំអន្តរាគមន៍ឆ្លើយតប
- ចូលរួមប្រមូលទិន្នន័យកុមាររងគ្រោះ កុមារងាយរងគ្រោះ កុមារងាយនឹងប្រព្រឹត្តបទល្មើស និងកុមារទំនាស់នឹងច្បាប់ដែលត្រូវបានដោះលែង ដើម្បីធ្វើផែនទីសេវាសង្គម និងធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម ដោយសហការជាមួយអាជ្ញាធរភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត
- ចូលរួមធ្វើការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យក្នុងសហគមន៍
- ចូលរួមប្រជុំជាមួយ គ.ក.ន.ក. ដើម្បីចែករំលែកព័ត៌មាន និងផ្ដល់ធាតុចូលសម្រាប់ធ្វើផែនការសកម្មភាព និងថវិកា ដើម្បីអនុវត្តកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- សហការជាមួយអ្នកអប់រំផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមសហគមន៍មូលដ្ឋាន
- សហការជាមួយផ្នែកអប់រំផ្សព្វផ្សាយ ក្រុមសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអនុវត្តវិធានការនៃកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់

- ធ្វើរបាយការណ៍ជូន អ.ក.ន.ក. ឱ្យបានទៀងទាត់ស្តីពីសកម្មភាពកិច្ចការពារកុមារ
- បំពេញកិច្ចការផ្សេងៗទៀតតាមការណែនាំពី គ.ក.ន.ក.។

ករណីរដ្ឋបាលឃុំ សង្កាត់មិនបានបង្កើតអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់ គ.ក.ន.ក. ត្រូវពិគ្រោះពិភាក្សាផ្ទៃក្នុង ដើម្បីធ្វើការបែងចែកភារកិច្ចខាងលើនេះជូនសមាជិករបស់ខ្លួន។

**៤. ក្រុមសហគមន៍មូលដ្ឋាន (ក.ស.ម.)**

រដ្ឋបាលឃុំ សង្កាត់ត្រូវបានលើកទឹកចិត្តឱ្យធ្វើការអប់រំ ណែនាំប្រជាពលរដ្ឋ ដើម្បីប្រមូលគ្នាចងក្រង ជាក្រុមសហគមន៍មូលដ្ឋាន។

ក្រុមសហគមន៍មូលដ្ឋាន សំដៅលើ**ក្រុមមាតាបិតា ក្រុមយុវជន ក្លឹបកុមារ និងក្រុមជំនឿសាសនា**។ល។ ក្រុមសហគមន៍មូលដ្ឋាននេះ អាចប្រែប្រួលទៅតាមឃុំ សង្កាត់នីមួយៗ។ ក្រុមសហគមន៍មូលដ្ឋានមានភារកិច្ចពាក់ព័ន្ធកិច្ចការពារកុមារដូចខាងក្រោម៖

- បង្កើនការយល់ដឹងអំពីកិច្ចការពារកុមារតាមរយៈការចែករំលែកចំណេះដឹងក្នុងក្រុម និងចូលរួមវគ្គអប់រំផ្សព្វផ្សាយ
- ចូលរួមតាមការស្ម័គ្រចិត្តក្នុងការផ្សព្វផ្សាយអប់រំ អំពីកិច្ចការពារកុមារនៅក្នុងសហគមន៍ ឬនៅក្នុងសាលារៀន
- ផ្តល់ព័ត៌មានអំពីករណីអំពើហិង្សាលើកុមារ កុមារងាយរងគ្រោះ និងកុមារបោះបង់ការសិក្សា ជូនដល់អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងសមាជិក គ.ក.ន.ក.
- ចូលរួមក្នុងការរៀបចំផែនការប្រចាំឆ្នាំ និងប្រចាំត្រីមាស ជាមួយសមាជិក គ.ក.ន.ក. ដើម្បីធ្វើសកម្មភាពបង្ការ និងទប់ស្កាត់អំពើហិង្សា និងការជួញដូរលើកុមារ
- ចូលរួមក្នុងកិច្ចការផ្សេងៗទៀតតាមការណែនាំពី អ.ក.ន.ក. ឬអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ។

**៥. អង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម**

ផ្អែកតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន រួមមានជាអាទិ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងយុត្តិធម៌ បាននិងកំពុងជំរុញកិច្ចគាំពារសង្គម ជាពិសេសកិច្ចការពារកុមារឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព។ ទន្ទឹមនេះ ក្រសួង ស្ថាប័នទាំងនោះបាន ឬគ្រោងរៀបចំឱ្យមានយន្តការនានាតាមវិស័យរបស់ខ្លួនក្នុងការជំរុញ ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ ដើម្បីធានាឱ្យការផ្តល់សេវាសង្គម ឬកិច្ចគាំពារសង្គមកាន់តែមានភាពល្អប្រសើរ។ ហេតុនេះ គ.ក.ន.ក. ត្រូវផ្តល់កិច្ចសហការ និងចូលរួមជាមួយយន្តការទាំងនោះក្នុងការផ្តល់សេវាសង្គម ឬកិច្ចគាំពារសង្គម ជាពិសេសកិច្ចការពាក់ព័ន្ធកុមារ។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចការពារកុមារនៅមូលដ្ឋាន និងងាយស្រួលក្នុងការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធនានានៃបណ្តាញកិច្ចការពារកុមារ អ្នកអនុវត្តសៀវភៅណែនាំនេះត្រូវរៀបចំបញ្ជីអ្នកពាក់ព័ន្ធកិច្ចការពារកុមារ ដោយប្រើប្រាស់***ឧបសម្ព័ន្ធទី៥***។

# ជំពូកទី៣

# វិធានការនៃកិច្ចការពារកុមារនៅឃុំ សង្កាត់

## ១. ការបង្ការអំពើហិង្សាលើកុមារ

ការបង្ការអំពើហិង្សា និងការរំលោភបំពានលើកុមារ តម្រូវឱ្យមានកិច្ចសហការគ្នាពីគ្រប់សមាសភាពពាក់ព័ន្ធទាំងអស់របស់បណ្តាញកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់ដែលរួមមាន គ.ក.ន.ក. សាលារៀន ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព ភូមិ អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ ក្រុមសហគមន៍មូលដ្ឋាន ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ព្រមទាំងមានការចូលរួមពីប្រជាពលរដ្ឋទូទៅ ការចូលរួមពីកុមារ និងគ្រួសាររបស់ពួកគេផ្ទាល់។ ដើម្បីបំពេញកិច្ចការនេះឱ្យបានល្អប្រសើរ សូមលើកទឹកចិត្តដល់ គ.ក.ន.ក. គួរអនុវត្តសកម្មភាពដូចតទៅ៖

### ១.១. *ការបណ្តុះបណ្តាលសមាជិក គ.ក.ន.ក. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងអ្នកពាក់ព័ន្ធ*

គ.ក.ន.ក. ត្រូវសហការ និងសម្របសម្រួលចាត់ចែងឱ្យមានវគ្គបណ្តុះបណ្តាលស្របតាមផែនការសកម្មភាពរបស់ខ្លួន ឬតាមរយៈការស្នើសុំការបណ្តុះបណ្តាលពីស្ថាប័នពាក់ព័ន្ធ ឬអង្គការដៃគូដែលមានចំណេះដឹង ជំនាញ និងបទពិសោធផ្នែកកិច្ចការពារកុមារ និងសង្គម ដើម្បីបណ្តុះបណ្តាលដល់សមាជិក គ.ក.ន.ក. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងអ្នកពាក់ព័ន្ធដទៃទៀត។

វគ្គបណ្តុះបណ្តាលនេះអាចប្រើប្រាស់កញ្ចប់ថវិការដ្ឋបាលឃុំ សង្កាត់ ឬស្នើសុំការគាំទ្រពីអង្គភាពផ្តល់សេវាសង្គម ឬកៀរគរធនធានពីអង្គការសង្គមស៊ីវិលដែលមានវត្តមាននៅក្នុងឃុំ សង្កាត់ និងដៃគូពាក់ព័ន្ធដទៃទៀត។

ប្រធានបទនៃការបណ្តុះបណ្តាលគួរផ្តោតទៅលើ៖

- ចំណេះដឹងមូលដ្ឋានស្តីពីការងារសង្គមកិច្ច
- ចំណេះដឹងមូលដ្ឋានស្តីពីកិច្ចការពារកុមារ
- ចំណេះដឹងមូលដ្ឋានស្តីពីការគ្រប់គ្រងករណី
- នីតិវិធីអន្តរាគមន៍បែបកុមារមេត្រី
- កុមារទំនាស់នឹងច្បាប់ (ច្បាប់យុត្តិធម៌អនីតិជន និងច្បាប់ពាក់ព័ន្ធកិច្ចការពារកុមារ)
- បទល្មើសកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ (Online Exploitation) លើកុមារ
- ផលប៉ះពាល់ពីការបែកចេញពីគ្រួសារ (ការថែទាំជំនួស)
- ការកាត់បន្ថយហានិភ័យនៃការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន
- ការអភិវឌ្ឍរបស់កុមារតាមដំណាក់កាល
- ការចិញ្ចឹមកូនបែបវិជ្ជមាន
- ការដាក់វិន័យសាលាបែបវិជ្ជមាន
- ការធ្វើផែនទីសេវាសង្គម
- ការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់កិច្ចការពារកុមារ

- ការដឹកនាំ និងការសម្របសម្រួលកិច្ចប្រជុំ
- ការរៀបចំវេទិកា
- ការនិយាយជាសាធារណៈ
- ការបំបែកកុមារចេញពីគ្រួសារដោយភាពមិនចាំបាច់
- ការគ្រប់គ្រងកំហឹង និងដំណោះស្រាយទន់ភ្លន់បែបវិជ្ជមាន។ល។

សមាជិក គ.ក.ន.ក. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវទទួលបានការបណ្តុះបណ្តាលចំពោះប្រធានបទណាមួយ ឬគ្រប់ប្រធានបទខាងលើ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកិច្ចការពារកុមារ ឬតួនាទី ភារកិច្ចរបស់អ្នកពាក់ព័ន្ធនីមួយៗ។

## ១.២. ការពង្រឹងសមត្ថភាពក្រុមសហគមន៍មូលដ្ឋាន

ករណីមានការបង្កើតនូវក្រុមសហគមន៍មូលដ្ឋាន គ.ក.ន.ក. (ផ្នែកអប់រំផ្សព្វផ្សាយនៃអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ) ត្រូវ ឬចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធធ្វើការពង្រឹងសមត្ថភាពដល់ក្រុមសហគមន៍មូលដ្ឋានសម្រាប់កិច្ចការពារកុមារ។ ការពង្រឹងសមត្ថភាពដល់ក្រុមសហគមន៍មូលដ្ឋាននេះត្រូវមានការគាំទ្រពី អ.ក.ន.ក. (សហការជាមួយផ្នែកផ្តល់សេវាសង្គមនៃអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ) និងដៃគូដទៃទៀតដែលមានវត្តមាននៅក្នុងឃុំ សង្កាត់។

កិច្ចការចម្បងក្នុងការពង្រឹងសមត្ថភាព គឺត្រូវរៀបចំកិច្ចប្រជុំជាទៀងរាល់ខែជាមួយសមាជិកក្រុមសហគមន៍មូលដ្ឋាន (ក្រុមមាតាបិតា ក្រុមយុវជន ក្លឹបកុមារ និងក្រុមជំនឿសាសនា...) ដើម្បីផ្តល់ចំណេះដឹង ចែករំលែកព័ត៌មាន ឆ្លុះបញ្ចាំងសកម្មភាពដែលបានអនុវត្ត និងដាក់ចេញជាផែនការសកម្មភាពសម្រាប់អនុវត្តខែបន្ទាប់អំពីកិច្ចការពារកុមារ។

ប្រធានបទដែលត្រូវលើកយកមកពិភាក្សាសម្រាប់ក្រុមនីមួយៗ រួមមាន៖

- **ក្រុមមាតាបិតា៖**
  - កិច្ចការពារកុមារ
  - សុខុមាលភាពឪពុកម្តាយ
  - ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ
  - កាតព្វកិច្ចរបស់ឪពុកម្តាយ និងភារកិច្ចរបស់កូន
  - ការចិញ្ចឹមកូនបែបវិជ្ជមាន
  - ការងារប្រចាំខែអំពីកិច្ចការពារកុមារ
- **ក្រុមយុវជន៖**
  - ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការរត់ពន្ធមនុស្ស
  - ហានិភ័យនៃការរត់ពន្ធមនុស្ស ពលកម្មកុមារ និងការកេងប្រវ័ញ្ចលើកុមារ
  - អនុសញ្ញាសិទ្ធិកុមារ
  - ទេសន្តរប្រវេសន៍ដែលមានសុវត្ថិភាព
  - គ្រប់ទម្រង់នៃអំពើហិង្សា
  - កញ្ចប់ការពារសុវត្ថិភាពកុមារ
  - បទល្មើសកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ (Online Exploitation) លើកុមារ
  - បណ្តាញគាំទ្ររបស់ខ្ញុំ

- សហគមន៍ដែលមានការគាំទ្រ
- ការងារប្រចាំខែអំពីកិច្ចការពារកុមារ

- **ក្លឹបកុមារ៖**
  - មូលដ្ឋានគ្រឹះនៃសហគមន៍មានសុវត្ថិភាព
  - សិទ្ធិ និងការទទួលខុសត្រូវ
  - ការគ្រប់គ្រងអារម្មណ៍
  - អំពើហិង្សាលើរាងកាយ
  - ជំនាញក្នុងការទំនាក់ទំនង
  - ការបៀតបៀនកេរខ្មាស
  - ការមិនអើពើលើកុមារ
  - ការបំពានផ្លូវភេទ
  - ពលកម្មកុមារ
  - សុវត្ថិភាពតាមបណ្តាញទំនាក់ទំនងសង្គម
  - ការងារប្រចាំខែអំពីកិច្ចការពារកុមារ
- **ក្រុមជំនឿសាសនា៖**
  - កិច្ចការពារកុមារ
  - ការថែរក្សាកុមារ និងគ្រួសារតាមសហគមន៍
  - ការប្រៀនប្រដៅកូនបែបវិជ្ជមាន
  - គោលនយោបាយវត្តសង្គហកុមារ
  - កម្មវិធីកិច្ចការពារកុមារតាមវត្តអារាម
  - ការប៉ាន់ប្រមាណហានិភ័យចំពោះកុមារនៅតាមវត្តអារាម
  - ការងារប្រចាំខែអំពីកិច្ចការពារកុមារ។

## ១.៣. ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងសហគមន៍

គ.ក.ន.ក. និងឬអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ ត្រូវសម្របសម្រួល និងសហការជាមួយអង្គភាព និងឬអង្គការដៃគូពាក់ព័ន្ធនានា ធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ និងកិច្ចការពារកុមារ ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានជាប្រចាំ ស្របតាមផែនការសកម្មភាពដែលបានកំណត់។ កិច្ចការចម្បងៗដែលត្រូវធ្វើមានដូចតទៅ៖

- រៀបចំដំណើរការសម្រាប់ការផ្សព្វផ្សាយនីមួយៗ ដូចជាការកំណត់ប្រធានបទ អ្នកសម្របសម្រួល អ្នកចូលរួម វិធីសាស្ត្រ ពេលវេលា និងទីកន្លែង។ល។
- ប្រមូលកៀរគរប្រជាពលរដ្ឋ កុមារ និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងឃុំ សង្កាត់ឱ្យចូលរួមក្នុងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងឱ្យបានទៀងទាត់តាមផែនការកំណត់។ ការផ្សព្វផ្សាយនេះ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំ វេទិកា និងការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាព័ត៌មាន។ល។
- ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងតាមសាលារៀនឱ្យបានទៀងទាត់ តាមផែនការកំណត់
- សហការជាមួយព្រះសង្ឃ និងក្រុមជំនឿសាសនាដទៃទៀត ដើម្បីអប់រំ ផ្សព្វផ្សាយទៅដល់សាសនិកជន។

## ១.៤. ការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងសហគមន៍

ការប៉ាន់ប្រមាណហានិភ័យនៃអំពើហិង្សា ការរំលោភបំពានកុមារ និងបញ្ហាកិច្ចការពារកុមារផ្សេងទៀត ដូចជាការបំបែកកុមារចេញពីគ្រួសារដោយភាពមិនចាំបាច់។ល។ គឺមានសារៈសំខាន់ក្នុងការរៀបចំវិធានការបង្ការមិនឱ្យបញ្ហាកើតឡើង។ គ.ក.ន.ក. ដោយមានអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងការចូលរួមពីក្រុមសហគមន៍មូលដ្ឋាន និងអ.ក.ន.ក.ជាជំនួយ ត្រូវសម្របសម្រួល ចូលរួមជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម រួមគ្នាធ្វើការប៉ាន់ប្រមាណហានិភ័យដូចខាងក្រោម៖

- រៀបចំផែនទីសេវាសង្គម ដើម្បីកំណត់រកកុមារងាយរងគ្រោះ ឬស្រង់សូចនាករពីផែនទីសេវាសង្គមដែលពាក់ព័ន្ធនឹងកុមារ ដូចជាកុមារទទួលរងអំពើហិង្សា កុមារកំព្រា កុមារមានពិការភាព កុមារអនាថា កុមារទំនាស់នឹងច្បាប់ដែលត្រូវបានដោះលែង ឬកុមារដែលរស់នៅជាមួយជីដូន ជីតាចាស់ជរា។ល។
- កំណត់មុខសញ្ញាដែលអាចបង្កហិង្សាលើកុមារដូចជា៖
  - បុគ្គលដែលធ្លាប់បង្កហិង្សា
  - បុគ្គលដែលប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀន។ល។
- កំណត់ទីតាំងដែលអំពើហិង្សាអាចកើតឡើង ឬអាចបង្កគ្រោះថ្នាក់ដល់កុមារ ដូចជាខ្នងផ្ទះ សាលារៀន និងសហគមន៍។ ទីតាំងសហគមន៍ដែលអាចបង្កបញ្ហាដល់កុមាររួមមាន៖
  - តំបន់ស្ងាត់ដាច់ស្រយាលហើយមានកុមារឆ្លងកាត់ ដូចជាទៅឃ្វាលគោ ទៅដងទឹក ឬទៅសាលារៀន
  - ប្រភពទឹក ដូចជាទន្លេ ស្ទឹង បឹង អូរ ត្រពាំង ឬប្រឡាយដែលអាចបង្កឱ្យកុមារលង់ទឹកដោយការធ្វេសប្រហែស
  - ផ្លូវដែលកុមារឆ្លងកាត់ដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍
  - ខ្សែភ្លើងធ្លាក់រប៉ាត់រប៉ាយដែលអាចឆក់កុមារ
  - កន្លែងសេវាកំសាន្ត
  - កន្លែងល្បែងកំសាន្ត និងល្បែងស៊ីសងខុសច្បាប់
  - កន្លែងដែលគ្រប់គ្នាគិតថាមានសុវត្ថិភាព (គ្រួសារដែលមានឪពុកចុង ឬម្ដាយចុង កន្លែងថែទាំកុមារ វត្តអារាម និងក្រុមសាសនាផ្សេងៗ)។

នៅពេលកំណត់ពីហានិភ័យរួចហើយ គ.ក.ន.ក. ត្រូវធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធនានា ដើម្បីរិះរកវិធានការដោះស្រាយសមស្របសម្រាប់ហានិភ័យនីមួយៗដែលបានរកឃើញ។

ឧទាហរណ៍៖

- ករណីបុគ្គលមួយចំនួនដែលធ្លាប់បង្កហិង្សា អាចផ្ដល់ការអប់រំឧបត្ថម្ភតាមលទ្ធភាព ឬអាចបញ្ចូលគាត់ទៅក្នុងក្រុមសហគមន៍មូលដ្ឋានកិច្ចការពារកុមារ ដើម្បីឱ្យបុគ្គលនោះប្រែក្លាយជាអ្នកបង្ការហិង្សាវិញ។
- ការដាក់ស្លាកសញ្ញាបង្ហាញពីគ្រោះថ្នាក់នៅតាមកន្លែងមានហានិភ័យផ្សេងៗ។

ការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យក្នុងសហគមន៍នេះ ត្រូវអនុវត្តជាប្រចាំ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

## ២. ការឆ្លើយតបទៅនឹងអំពើហិង្សា

### ២.១. វិធីសាស្ត្ររួម

គ.ក.ន.ក. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ និងឬ អ.ក.ន.ក. គឺជាអ្នកដឹកនាំ សម្របសម្រួលការឆ្លើយតបនៅថ្នាក់ឃុំ សង្កាត់ចំពោះរាល់ទម្រង់នៃអំពើហិង្សា និងការរំលោភបំពានលើកុមារ ដែលតម្រូវឱ្យមានការចូលរួមពីកុមារ និងគ្រួសាររបស់ពួកគេផ្ទាល់។ គ.ក.ន.ក. ត្រូវកៀរគរកិច្ចសហការ និងការឧបត្ថម្ភគាំទ្រពីស្ថាប័នពាក់ព័ន្ធ ដូចជាមណ្ឌលសុខភាព សាលារៀន ប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ រដ្ឋបាលថ្នាក់ក្រោមជាតិ(រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មន្ទីរសុខាភិបាល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរអប់រំ យុវជន និងកីឡា និងសាលាដំបូងរាជធានី ខេត្ត ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងស្ថាប័ននានាដែលមានការងារពាក់ព័ន្ធនៅក្នុងឃុំ សង្កាត់។ ភារកិច្ចរបស់អង្គភាព និងឬអ្នកពាក់ព័ន្ធក្នុងការឆ្លើយតបរាល់ទម្រង់នៃអំពើហិង្សា និងការរំលោភបំពានលើកុមាររួមមាន៖

- អ.ក.ន.ក. ឬអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ ក្រុមសហគមន៍មូលដ្ឋាន ឬប្រជាពលរដ្ឋត្រូវរាយការណ៍ជូនសមាជិក គ.ក.ន.ក. អំពីករណីហិង្សាលើកុមារ ដូចជាកុមារដែលគេបោះបង់ចោល កុមាររងាយរងគ្រោះ ឬកុមារដែលបានទទួលរងអំពើហិង្សា។ល។
- អង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ត្រូវជួយ គ.ក.ន.ក. វាយតម្លៃបឋមករណីអំពើហិង្សាលើកុមារ និងជួយអន្តរាគមន៍បឋម ដើម្បីធានាថាកុមារមានសុវត្ថិភាព។
- ស្ថាប័នផ្តល់សេវាសង្គមត្រូវផ្តល់សេវាដោយផ្ទាល់ដល់កុមាររងគ្រោះ។ ស្ថាប័នផ្តល់សេវាសង្គមរួមមានស្ថាប័នរាជរដ្ឋាភិបាល(មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមូលដ្ឋានផ្តល់សេវាសុខាភិបាល និងឬអង្គភាពផ្តល់សេវាសង្គមដទៃទៀតដែលបានបង្កើតឡើងស្របតាមច្បាប់) និងអង្គការសង្គមស៊ីវិល ព្រមទាំងសាធារណជន ដែលមានសមានចិត្តក្នុងការបីបាច់ថែទាំដល់កុមារជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ដោយស្របតាមនីតិវិធីច្បាប់
- ក្នុងករណីដែលរកឃើញថាជាបទល្មើសព្រហ្មទណ្ឌ អ្នកពាក់ព័ន្ធត្រូវបញ្ជូនសំណុំរឿង ភស្តុតាង និងជនរងគ្រោះទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ដែលមានទីតាំងជិតបំផុត។

ដើម្បីអនុវត្តវិធីសាស្ត្រ ឬនីតិវិធីនៃការឆ្លើយតបរាល់ទម្រង់នៃអំពើហិង្សា និងការរំលោភបំពានលើកុមារឱ្យមានប្រសិទ្ធភាព អ្នកអនុវត្ត និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ក្នុងការឆ្លើយតបដូចខាងក្រោម៖

***១. ត្រូវធានាថាកុមារមានសុវត្ថិភាព***

***២. ត្រូវបញ្ជូនកុមារទៅសេវាសង្គ្រោះបន្ទាន់ក្នុងករណីចាំបាច់ដើម្បីសង្គ្រោះជីវិត***

***៣. ត្រូវគិតពីឧត្តមប្រយោជន៍របស់កុមារ***

***៤. ត្រូវរក្សាការសម្ងាត់។***


ការរាយការណ៍ពីកុមាររងគ្រោះទៅមនុស្សពេញវ័យ និងអាជ្ញាធរ
ការឆ្លើយតបបន្ទាន់ និងការវាយតម្លៃពីតម្រូវការកុមាររងគ្រោះ
ការបញ្ជូនកុមាររងគ្រោះឲ្យទៅទទួលសេវាពីស្ថាប័នពាក់ព័ន្ធ
ការផ្តល់សេវានិង/ឬការស្តារនីតិសម្បទាកុមាររងគ្រោះឡើងវិញ
កុមារ
គ្រួសារ មិត្តភក្តិ អ្នកជិតខាង សាលារៀន សហគមន៍
ភូមិ (មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ)
នគរបាលជាតិ 1288 និង នគរបាលថ្នាក់ក្រោមជាតិ
បណ្តាញទូរស័ព្ទជំនួយកុមារ 1280
អ.ក.ន.ក. អ.ទ.ក. ក.ស.ម.
អ.ក.ន.ក. អ្នកសម្របសម្រួលកិច្ចការពារកុមារ និងអង្គការពាក់ព័ន្ធ វាយតម្លៃតម្រូវការ និងបញ្ជូនបន្ត
ការអន្តរាគមន៍ផ្នែកច្បាប់
បញ្ជូនទៅទទួលសេវាសង្គម
មេឃុំ ចៅសង្កាត់
ប៉ុស្តិ៍នគរបាលរដ្ឋបាល
អភិបាលរងក្រុង ស្រុក ខណ្ឌ
អធិការដ្ឋាននគរបាល
អធិការដ្ឋាននគរបាលទទួលបន្ទុកប្រឆាំងការជួញដូរ និងកិច្ចការពារកុមារ
អភិបាលរងរាជធានី ខេត្ត
ស្នងការដ្ឋាននគរបាល
ស្នងការដ្ឋាននគរបាលទទួលបន្ទុកប្រឆាំងការជួញដូរ និងកិច្ចការពារកុមារ
តុលាការ (ព្រះរាជអាជ្ញា)
គ.ក.ន.ក. ឃុំ សង្កាត់
គ.ក.ស.ក. ក្រុង ស្រុក ខណ្ឌ
គ.ក.ស.ក. រាជធានី ខេត្ត
មន្ទីរពេទ្យបង្អែក (ផ្នែកកោសល្យវិច្ច័យ)
សេវាគាំទ្រផ្សេងៗផ្អែកតាមតម្រូវការរបស់កុមារដែលផ្តល់ដោយស្ថាប័ននានា
សេវាសម្រាប់អ្នកមានវិបត្តិជីវកសុវត្ថិភាព
ជំនួយផ្នែកច្បាប់
ការផ្តល់ប្រឹក្សាផ្នែកសង្គម និងចិត្តសាស្ត្រ
បំណិនជីវិត ការអប់រំ បណ្តុះបណ្តាល

## ២.២. ជំហាននៃការដោះស្រាយករណីអំពើហិង្សាលើកុមារ

អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ (អ.ទ.ក.) និងគ.ក.ន.ក. ត្រូវចាត់ចែង និងដោះស្រាយសេចក្តីត្រូវការរបស់កុមារម្នាក់ៗ និងគ្រួសាររបស់ពួកគេឱ្យបានសមស្រប ទាន់ពេលវេលា និងមានលក្ខណៈជាប្រព័ន្ធតាមរយៈការជួយគាំទ្រដោយផ្ទាល់ និងឬបញ្ជូនទៅកន្លែងផ្តល់សេវាតាមករណីជាក់ស្តែង។ គ.ក.ន.ក. ត្រូវចូលរួម និងសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធដែលមានសមត្ថកិច្ច ធ្វើការឆ្លើយតបឬដោះស្រាយករណីនៃអំពើហិង្សា ដោយអនុវត្តជំហានដូចខាងក្រោម៖

- ការកំណត់ករណីអំពើហិង្សា និងការចុះបញ្ជី
- ការវាយតម្លៃអំពើហិង្សា
- ការរៀបចំផែនការដោះស្រាយអំពើហិង្សា
- ការអនុវត្តផែនការដោះស្រាយអំពើហិង្សា
- ការតាមដាន និងពិនិត្យឡើងវិញ
- ការបិទបញ្ចប់ករណី។

### ជំហានទី១៖ ការកំណត់ករណីអំពើហិង្សា និងការចុះបញ្ជី

គ.ក.ន.ក. អង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម អាចទទួលបានព័ត៌មាន ឬការរាយការណ៍ពីអំពើហិង្សាលើកុមារតាមរយៈ៖

- មាតាបិតា អាណាព្យាបាល
- កុមាររងគ្រោះផ្ទាល់
- មិត្តភក្តិរបស់កុមាររងគ្រោះ
- អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ ក្រុមសហគមន៍មូលដ្ឋាន ឬប្រជាពលរដ្ឋទូទៅ
- មណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលបានពិនិត្យកុមារ
- គ្រូបង្រៀន។

បន្ទាប់ពីទទួលបានព័ត៌មាន និងពិនិត្យរកឃើញថាកុមារពិតជាបានទទួលរងនូវអំពើហិង្សាប្រាកដមែន គ.ក.ន.ក. ត្រូវចាត់ អ.ក.ន.ក. ឱ្យសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គមនៅមូលដ្ឋាន បំពេញទម្រង់ចុះបញ្ជីករណីនៃ ***ឧបសម្ព័ន្ធទី២.ក*** និងបញ្ជីកត់ត្រាករណីនៃ ***ឧបសម្ព័ន្ធទី២.ខ***។

### ជំហានទី២៖ ការវាយតម្លៃអំពើហិង្សា

អ.ក.ន.ក សហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ត្រូវធ្វើការវាយតម្លៃដោយផ្តោតលើកត្តាបង្កគ្រោះថ្នាក់ ស្ថានភាពកុមារ និងគ្រួសារ ក្នុងការទប់ទល់នឹងអំពើហិង្សា។ ការវាយតម្លៃនឹងនាំទៅដល់ការធ្វើអន្តរាគមន៍ជួយកុមារ ហើយការធ្វើអន្តរាគមន៍ ឬក៏ការឆ្លើយតបនោះ គឺស្របទៅតាមស្ថានភាពហានិភ័យជាក់ស្តែងធ្ងន់ ឬស្រាលរបស់កុមារដែលបានទទួលរងនូវអំពើហិង្សា។ ការវាយតម្លៃចែកជាពីរដំណាក់កាលគឺ៖

- **ដំណាក់កាលទី១៖** ការវាយតម្លៃបឋម គឺអាចនាំដល់ការធ្វើអន្តរាគមន៍ភ្លាមៗ ដើម្បីការពាររាងកាយ និងជានាសុវត្ថិភាពរបស់កុមារ និងបំពេញតម្រូវការជាក់ស្តែង ដូចជាអាហារ ជម្រក និងការថែទាំផ្នែកវេជ្ជសាស្ត្រ។ ការវាយតម្លៃនេះ ត្រូវពិនិត្យឱ្យបានត្រឹមត្រូវ និងជាក់លាក់លើកម្រិតនៃអំពើហិង្សា ដើម្បីឆ្លើយតប និងធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលា។

**តារាងបង្ហាញពីស្ថានភាពជាក់ស្តែងរបស់កុមារ និងកម្រិតនៃការធ្វើអន្តរាគមន៍**

| កម្រិតអំពើហិង្សា | បរិយាយ | រយៈពេលនៃការឆ្លើយតប |
|---|---|---|
| ធ្ងន់ធ្ងរ | កុមារត្រូវការសេវាពិនិត្យព្យាបាលបន្ទាន់ ដូច្នេះ ត្រូវបញ្ជូនកុមារទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ។ | អន្តរាគមន៍ត្រូវធ្វើភ្លាមៗ |
| មធ្យម | កុមារបានទទួលរងនូវអំពើហិង្សាក្នុងកម្រិតណាមួយ ដែលតម្រូវឱ្យមានអន្តរាគមន៍ ប៉ុន្តែមិនមានសញ្ញាណាមួយបង្ហាញថាកុមារមានហានិភ័យខ្ពស់ទេ។ | អន្តរាគមន៍អាចធ្វើឡើងក្នុងរង្វង់៧២ម៉ោង |
| ស្រាល | លំនៅឋានអាចមានសុវត្ថិភាពដល់កុមារ ប៉ុន្តែកុមារអាចរងនូវអំពើហិង្សា បើសិនជាមិនជួយអន្តរាគមន៍ការពារទេ។ | អន្តរាគមន៍អាចធ្វើឡើងក្នុងរង្វង់១សប្តាហ៍ |

- **ដំណាក់កាលទី២៖** ការវាយតម្លៃគ្រប់ជ្រុងជ្រោយ គឺជាការវាយតម្លៃបន្ទាប់ពីការវាយតម្លៃបឋម និងបន្ទាប់ពីផ្តល់សេវាបន្ទាន់ដល់កុមាររួច។ ការវាយតម្លៃនេះ គឺពិនិត្យមើលស្ថានភាពកុមារឱ្យបានស៊ីជម្រៅលើសពីសេចក្តីត្រូវការចំពោះមុខរបស់កុមារ ដូចជាសេវាដែលមានសម្រាប់កុមារ ការសិក្សា ភាពក្រីក្រ សមត្ថភាពមាតាបិតាក្នុងកិច្ចការពារកុមារ សមត្ថភាពកុមារក្នុងការទប់ទល់នឹងអំពើហិង្សា។ល។

## ជំហានទី៣៖ ការរៀបចំផែនការដោះស្រាយអំពើហិង្សា

តាមរយៈការវាយតម្លៃក្នុងជំហានទី២ អ.ក.ន.ក. ត្រូវសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម កំណត់តម្រូវការចំបាច់របស់កុមាររងគ្រោះដូចជា៖

- តម្រូវការសេវាផ្នែកវេជ្ជសាស្ត្រ
- តម្រូវការផ្នែកចិត្តសាស្ត្រ
- តម្រូវការសេវាផ្នែកច្បាប់
- តម្រូវការសម្រាប់អភិវឌ្ឍន៍
- តម្រូវការក្នុងការថែទាំ និងការពារ
- តម្រូវការក្នុងការរួមរស់នៅក្នុងសហគមន៍វិញ
- តម្រូវការផ្នែកសេដ្ឋកិច្ច
- តម្រូវការផ្សេងៗទៀត។

អ.ក.ន.ក. សហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ត្រូវស្វែងរកដំណោះស្រាយស្របទៅតាមស្ថានភាពជាក់ស្តែង និងតម្រូវការរបស់កុមាររងគ្រោះ។

ផ្អែកតាមតម្រូវការខាងលើ អ.ក.ន.ក. ត្រូវរាយការណ៍ជូនប្រធាន គ.ក.ន.ក.។ ប្រធាន គ.ក.ន.ក. ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីប្រជុំពិភាក្សាជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គមធ្វើការរៀបចំផែនការសកម្មភាពឆ្លើយតប ដោយកំណត់ឱ្យបានជាក់លាក់នូវវិធានការដោះស្រាយ ស្ថាប័នទទួលខុសត្រូវ ការចំណាយ ប្រភពថវិកា និងពេលវេលាអនុវត្ត។

## ជំហានទី៤៖ ការអនុវត្តផែនការដោះស្រាយអំពើហិង្សា

អ.ក.ន.ក. និងឬអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ គឺជាអ្នកទទួលខុសត្រូវរួមក្នុងការសម្របសម្រួល ដោះស្រាយបញ្ហារបស់កុមាររងគ្រោះដោយសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការ ៥

សេវាសង្គម អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ដែលធ្វើសកម្មភាពក្នុងឃុំ សង្កាត់ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីអនុវត្តផែនការដោះស្រាយ ជាពិសេសរួមមានសកម្មភាពដូចជា៖

- សម្របសម្រួលការផ្តល់សេវាជូនដល់កុមារភ្លាមៗ ដើម្បីឆ្លើយតបតាមតម្រូវការជាបន្ទាន់របស់កុមាររងគ្រោះ
- រៀបចំដំណោះស្រាយអំពើហិង្សាទៅក្នុងផែនការបណ្តាញកិច្ចការពារកុមារក្នុងជំពូកទី៤ និងសម្រាប់ដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

## ជំហានទី៥៖ ការតាមដាន និងការពិនិត្យឡើងវិញ

ការតាមដាន និងការពិនិត្យឡើងវិញ ត្រូវធ្វើឡើងជាបន្តបន្ទាប់ក្នុងអំឡុងពេល និងក្រោយពេលអនុវត្តផែនការដោះស្រាយអំពើហិង្សា។ កិច្ចការនេះត្រូវអនុវត្តដោយ អ.ក.ន.ក. និងឬអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ អង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដោយត្រូវប្រើប្រាស់សំណួរដូចខាងក្រោមដើម្បីតាមដាន និងពិនិត្យឡើងវិញ៖

✓ តើកុមារ និងគ្រួសារ បានទទួលការគាំទ្រ និងសេវាសមស្របដែរឬទេ?
✓ តើស្ថានភាពកុមារ និងស្ថានភាពគ្រួសារមានការប្រែប្រួលអ្វីខ្លះ?
✓ តើទំនាក់ទំនងរវាងកុមារ និងមាតាបិតា ឬអាណាព្យាបាលយ៉ាងដូចម្តេចដែរ?
✓ តើកុមារបានត្រឡប់ចូលសាលារៀនវិញហើយឬនៅ?

គ.ក.ន.ក. ត្រូវរៀបចំកិច្ចប្រជុំជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យផែនការឡើងវិញថា តើដំណោះស្រាយសម្រាប់ករណីនីមួយៗសម្រេចបានតាមផែនការគ្រោងទុកដែរឬទេ និងលើកអនុសាសន៍សមស្របបន្ថែមទៀត ដើម្បីកិច្ចការពារកុមារ។

## ជំហានទី៦៖ ការបិទបញ្ចប់ករណី

ការបិទបញ្ចប់ករណី អាចបណ្តាលមកពីកត្តាជាច្រើនដូចជា៖

- ករណីកុមារត្រូវបានដោះស្រាយចប់សព្វគ្រប់ ហើយកុមារលែងត្រូវការជំនួយបន្ថែមទៀត
- កុមារត្រូវបានបញ្ជូនទៅរស់នៅជាមួយគ្រួសាររបស់កុមារ ឬអង្គការ ឬស្ថាប័នដែលទទួលខុសត្រូវ
- កុមារបានផ្លាស់ប្តូរទីកន្លែងរស់នៅ ឬ
- កុមារបានស្លាប់។ល។



៥

### ជំហានសង្ខេបនៃការដោះស្រាយករណីហិង្សាលើកុមារ




### ៣. ការបញ្ជូនកុមាររងគ្រោះទៅរកសេវា

គ.ក.ន.ក. ត្រូវចាត់ អ.ក.ន.ក. ឬសមាជិក គ.ក.ន.ក. ឱ្យទទួលខុសត្រូវចូលរួមសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធក្នុងការសម្របសម្រួលបញ្ជូនកុមាររងគ្រោះដោយអំពើហិង្សាទៅរកសេវាសមស្រប ដោយត្រូវសុំការយល់ព្រម និងទទួលបានការយល់ព្រមពីកុមារ និងមាតាបិតា ឬអាណាព្យាបាល លើកលែងតែក្នុងករណីចាំបាច់ដែលត្រូវសង្គ្រោះជីវិតបន្ទាន់។ កុមាររងគ្រោះដោយអំពើហិង្សាអាចត្រូវការសេវាចាំបាច់ផ្សេងៗ ដូចជាការព្យាបាល ការថែទាំសុខភាព ការការពារផ្នែកច្បាប់ ការស្នាក់នៅ ការផ្តល់ម្ហូបអាហារ ការឧបត្ថម្ភគាំទ្រផ្នែកសង្គមកិច្ចនិងចិត្តសាស្ត្រ និងឬការអភិវឌ្ឍបំណិនជីវិតជាដើម។ ការបញ្ជូនអាចមានពីរប្រភេទដូចខាងក្រោម៖

- ការបញ្ជូនផ្ទៃក្នុង គឺជាការបញ្ជូនក្នុងបណ្តាញ គ.ក.ន.ក.។ ឧទាហរណ៍៖ អ.ក.ន.ក ឬក្រុមសហគមន៍មូលដ្ឋាន ឬអ្នកពាក់ព័ន្ធបញ្ជូនកុមារពីភូមិកើតហេតុទៅមណ្ឌលសុខភាព ឬទៅជួបនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ដើម្បីផ្តល់ចម្លើយជាភស្តុតាងបន្ថែម។ល។
- ការបញ្ជូនពីស្ថាប័នមួយទៅស្ថាប័នមួយទៀត។ ឧទាហរណ៍៖ ការបញ្ជូនកុមាររងគ្រោះពីមន្ទីរពេទ្យទៅមណ្ឌលស្នាក់នៅ ឬទៅទទួលការថែទាំបន្តពីអង្គការដៃគូ។ល។

អ.ក.ន.ក. និងអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ត្រូវធានាថា ទម្រង់បញ្ជូនកុមាររងគ្រោះក្នុង ***ឧបសម្ព័ន្ធទី៣.ក*** បានបំពេញត្រឹមត្រូវដោយអ្នកបញ្ជូនរាល់ការបញ្ជូនពីស្ថាប័នមួយទៅស្ថាប័នមួយ។ រាល់ការបញ្ជូនទាំងអស់ ត្រូវភ្ជាប់មកជាមួយទម្រង់ផ្តល់យោបល់ត្រឡប់ស្តីពីការបញ្ជូនកុមារក្នុង ***ឧបសម្ព័ន្ធទី៣.ខ*** ។

### ៩. ការធ្វើសមាហរណកម្មកុមារ

ការធ្វើសមាហរណកម្មកុមារ គឺជាដំណើរការមួយបង្កលក្ខណៈឱ្យកុមារបានវិលត្រឡប់ទៅរស់នៅក្នុងគ្រួសារ សហគមន៍តាមការជ្រើសរើសរបស់កុមាររងគ្រោះ បើសិនជាគាត់ធ្លាប់បានរស់នៅក្នុងមណ្ឌលថែទាំ ឬបានចេញឆ្ងាយពីផ្ទះ។

គ.ក.ន.ក. ត្រូវសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ដើម្បីធ្វើសមាហរណកម្មកុមារចូលទៅរស់នៅក្នុងសហគមន៍វិញ។ ការធ្វើសមាហរណកម្មកុមារនេះ ត្រូវគោរព និងអនុវត្តតាមការណែនាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ការធ្វើសមាហរណកម្មកុមារចូលទៅរស់នៅក្នុងគ្រួសារ និងសហគមន៍វិញ ត្រូវប្រព្រឹត្តទៅតាមបួនដំណាក់កាលដូចខាងក្រោម៖

#### *ដំណាក់កាលទី១ ៖ មុនសមាហរណកម្ម*

ដំណាក់កាលមុនពេលសមាហរណកម្ម ឬមុនពេលបញ្ជូនកុមារត្រឡប់ទៅរួមរស់ជាមួយគ្រួសារ ឬសហគមន៍វិញ គ.ក.ន.ក. ត្រូវសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គមត្រូវមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ស្វែងរកគ្រួសាររបស់កុមារដែលរងគ្រោះ ឬគ្រួសារចិញ្ចឹមកុមារ
- វាយតម្លៃអំពីស្ថានភាពគ្រួសារ និងសហគមន៍
- ជួយសម្របសម្រួលការធ្វើសមាហរណកម្ម
- រៀបចំសេវាគាំទ្រផ្នែកសង្គមដល់កុមារ និងគ្រួសារ។

#### *ដំណាក់កាលទី២ ៖ សមាហរណកម្ម*

គ.ក.ន.ក. ត្រូវសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ពិគ្រោះពិភាក្សាជាមួយគ្រួសារដែលទទួលកុមារទៅរួមរស់វិញ មន្ត្រីសង្គមកិច្ចដែលទទួលបន្ទុកសមាហរណកម្មកុមារ និងបុគ្គលិករបស់អង្គការ ឬមណ្ឌលដែលមើលថែទាំកុមារ ដើម្បីកំណត់កាលបរិច្ឆេទក្នុងការរៀបចំ សមាហរណកម្មកុមារទៅរួមរស់ជាមួយគ្រួសារ ឬគ្រួសារចិញ្ចឹមវិញ។

អ.ក.ន.ក. ត្រូវរៀបចំកិច្ចព្រមព្រៀងសមាហរណកម្មកុមារ ***(ឧបសម្ព័ន្ធទី៤៖ ទម្រង់ទុកដាក់កុមារ)*** ជាមួយគ្រួសារដែលទទួលយកកុមារទៅចិញ្ចឹម។ កិច្ចព្រមព្រៀងនេះត្រូវធ្វើ៣ (បី) ច្បាប់ ដែលមួយច្បាប់រក្សាទុកនៅគ្រួសារដែលទទួលកុមារ មួយច្បាប់ទុកនៅមន្ត្រីសង្គមកិច្ច និងមួយច្បាប់ទៀតរក្សាទុកនៅ គ.ក.ន.ក.។

## ដំណាក់កាលទី៣ ៖ ការតាមដានប្រភេទទី១

ការចុះតាមដានប្រភេទទី១ គឺជារយៈពេលដែលផែនការគាំទ្រត្រូវបានអនុវត្ត និងសេវានានានៅក្នុងផែនការនេះត្រូវបានផ្តល់ឱ្យកុមារដែលត្រូវបានធ្វើសមាហរណកម្ម។ គ.ក.ន.ក. ត្រូវសហការជាមួយអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម ត្រូវចុះពិនិត្យតាមដានដល់ផ្ទះកុមារដែលបានធ្វើសមាហរណកម្មលើកទី១ ក្នុងរយៈពេល២ (ពីរ) សប្តាហ៍ក្រោយធ្វើសមាហរណកម្ម និងការចុះពិនិត្យតាមដានជាបន្តបន្ទាប់មកទៀតអាចធ្វើឡើងជាប្រចាំយ៉ាងហោចណាស់១ (មួយ) ខែម្តង។

## ដំណាក់កាលទី៤ ៖ ការតាមដានប្រភេទទី២

ការតាមដានប្រភេទទី២ គឺជាការវាយតម្លៃអំពីស្ថានភាពរបស់កុមារ ស្ថានភាពរបស់គ្រួសារ បញ្ហានានា និងលទ្ធផលសម្រេចបានតាមការគ្រោងទុក។ ក្នុងករណីកុមារមានស្ថានភាពនឹងនហើយ គឺមានន័យថាសមាហរណកម្មមានស្ថិរភាពបាន១ (មួយ) ឆ្នាំ ហើយទំនាក់ទំនងក្នុងគ្រួសាររបស់កុមារបានប្រសើរឡើង ការតាមដាននេះអាចបញ្ចប់ឬត្រូវបិទករណី។

ក្នុងករណីពុំទាន់សម្រេចបានលទ្ធផលល្អទេ ត្រូវតាមដានបន្តទៀត ហើយត្រូវកំណត់រកបញ្ហា និងដោះស្រាយបញ្ហាទាំងនោះ ដើម្បីសម្រេចគោលដៅនៃការធ្វើសមាហរណកម្មកុមារ។ កិច្ចការនេះត្រូវអនុវត្តដោយ គ.ក.ន.ក. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ អង្គភាព និងឬអ្នកពាក់ព័ន្ធដទៃទៀត។

## ជំពូកទី៤

## ការដាក់បញ្ចូលកិច្ចការពារកុមារទៅក្នុងផែនការសកម្មភាព និងថវិកាឃុំ សង្កាត់

ដើម្បីអនុវត្តកិច្ចការពារកុមារនៅថ្នាក់មូលដ្ឋានឱ្យមានប្រសិទ្ធភាព គ.ក.ន.ក. ត្រូវដឹកនាំសម្របសម្រួល និងកៀរគរអង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ឱ្យចូលរួមក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពសម្រាប់កិច្ចការពារកុមារ ដោយត្រូវយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពសេវាសង្គមប្រចាំឆ្នាំ និងត្រីមាស ដោយខិតខំដាក់បញ្ចូលសកម្មភាពកិច្ចការពារកុមារ
- គ្រោងថវិកាសម្រាប់ប្រើប្រាស់លើសកម្មភាពកិច្ចការពារកុមារទៅក្នុងផែនការថវិកាសេវាសង្គមប្រចាំឆ្នាំ និងត្រីមាស
- សំណូមពរដល់អង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គម អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ឱ្យគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ក.ន.ក. សម្រាប់ប្រើប្រាស់លើវិស័យសេវាសង្គម ជាពិសេសកិច្ចការពារកុមារ
- ផ្តល់យោបល់ដល់អង្គភាព និងឬអ្នកពាក់ព័ន្ធកិច្ចការសេវាសង្គមក្នុងការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ប្រើប្រាស់លើវិស័យសេវាសង្គម ជាពិសេសកិច្ចការពារកុមារ
- ចូលរួមក្នុងដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដើម្បីដាក់បញ្ចូលបញ្ហា និងតម្រូវការនៃកិច្ចការពារកុមារ។

ក្រៅពីសកម្មភាពខាងលើនេះ គ.ក.ន.ក. ត្រូវយកចិត្តទុកដាក់លើសកម្មភាពកិច្ចការពារកុមារដូចខាងក្រោម៖

- អប់រំ ផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃកិច្ចការពារកុមារ
- អប់រំអំពីការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយភាពមិនចាំបាច់ និងការបង្រួបបង្រួមគ្រួសារ
- តាមដាន និងគាំទ្រដល់កុមារដែលបានបោះបង់ការសិក្សា ដើម្បីផ្តល់លទ្ធភាពឱ្យពួកគេបានចូលរៀនវិញ
- បណ្តុះបណ្តាលកសាងសមត្ថភាពដល់សមាជិក គ.ក.ន.ក. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ ក្រុមសហគមន៍មូលដ្ឋាន អង្គភាព និងឬអ្នកពាក់ព័ន្ធ
- កម្មវិធីជួបក្រុមមាតាបិតា ឬអាណាព្យាបាល ក្លឹបកុមារ ក្រុមយុវជន ក្រុមជំនឿសាសនា...
- បញ្ជូនកុមាររងគ្រោះទៅទទួលសេវា
- តាមដាន ត្រួតពិនិត្យការអនុវត្តសកម្មភាពកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់។

**សម្គាល់៖**

- ❖ ចំពោះនីតិវិធីស្តីពីការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកា ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងការរៀបចំរបាយការណ៍លទ្ធផលនៃការអនុវត្តសកម្មភាពកិច្ចការពារកុមារត្រូវអនុវត្តតាម **«សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់»** ដែលបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨ ចាប់ពីជំពូកទី២ដល់ជំពូកទី៤។
- ❖ ចំពោះសកម្មភាពបន្ទាន់ណាមួយ ដែលមិនបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិកា ស្ថាប័នពាក់ព័ន្ធអាចរៀបចំ និងអនុវត្តសកម្មភាពនោះ ដោយប្រើប្រាស់ថវិការបស់ខ្លួន ដើម្បីធានាដល់ការធ្វើអន្តរាគមន៍សង្គ្រោះកុមាររងគ្រោះឱ្យបានទាន់ពេលវេលា។

**ឧបសម្ព័ន្ធទី១ ៖ សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត.............**

**ក្រុង ស្រុក ខណ្ឌ...........**

**រដ្ឋបាលឃុំ សង្កាត់...............**

**លេខ.............ស.ស.រ.**

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារ

**មេឃុំ ឬចៅសង្កាត់....................**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញប្រកាសលេខ............ ចុះថ្ងៃទី...... ខែ........ ឆ្នាំ២០... របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំក្រុមប្រឹក្សាឃុំ..........ថ្ងៃទី..........ខែ.......ឆ្នាំ..........

## សម្រេច

**ប្រការ១ ._**

តែងតាំងអ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់.....................ដែលមានសមាសភាពដូចខាងក្រោម៖

១.លោក លោកស្រី.................................... ទទួលបន្ទុកជាអ្នកអប់រំផ្សព្វផ្សាយ

២.លោក លោកស្រី.................................... ទទួលបន្ទុកជាអ្នកផ្តល់សេវាសង្គម

**ប្រការ២ ._**

**អ្នកអប់រំផ្សព្វផ្សាយ** មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជួយ **អ.ក.ន.ក.** ក្នុងការបំពេញតួនាទី ភារកិច្ចក្នុងកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ និងទប់ស្កាត់អំពើហិង្សាលើកុមារតាមរយៈការអប់រំផ្សព្វផ្សាយ
- រាយការណ៍ពីករណីអំពើហិង្សាលើកុមារទៅ **អ.ក.ន.ក.** ឬអ្នកពាក់ព័ន្ធ ដើម្បីសុំការអន្តរាគមន៍
- ចូលរួមប្រមូលទិន្នន័យកុមាររងគ្រោះ កុមារងាយរងគ្រោះ កុមារងាយនឹងប្រព្រឹត្តបទល្មើស និងកុមារទំនាស់នឹងច្បាប់ដែលត្រូវបានដោះលែង ដើម្បីធ្វើផែនទីសេវាសង្គម និងធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម ដោយសហការជាមួយអាជ្ញាធរភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត
- ចូលរួមធ្វើការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យក្នុងសហគមន៍
- ចូលរួមប្រជុំជាមួយ **គ.ក.ន.ក.** ដើម្បីចែករំលែកព័ត៌មាន និងផ្តល់ធាតុចូលសម្រាប់ធ្វើផែនការសកម្មភាព និងថវិកា ដើម្បីអនុវត្តកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមសហគមន៍មូលដ្ឋានដែលរួមមានក្រុមមាតាបិតា ក្រុមយុវជន ក្លឹបកុមារ ក្រុមជំនឿសាសនា។ល។
- ដឹកនាំ សម្របសម្រួលពិភាក្សាជាមួយក្រុមសហគមន៍មូលដ្ឋាន ដោយមានការគាំទ្រពី **អ.ក.ន.ក.** និងអ្នកពាក់ព័ន្ធ ដើម្បីកំណត់ ឬកែសម្រួលភារកិច្ចរបស់ក្រុមសហគមន៍មូលដ្ឋានអំពីកិច្ចការពារកុមារនៅមូលដ្ឋាន
- សហការជាមួយអ្នកផ្តល់សេវាសង្គម ក្រុមសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអនុវត្តវិធានការនៃកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- ធ្វើរបាយការណ៍ជូន **អ.ក.ន.ក.** ឱ្យបានទៀងទាត់ស្តីពីសកម្មភាពកិច្ចការពារកុមារ
- បំពេញកិច្ចការផ្សេងៗទៀតតាមការណែនាំពី **គ.ក.ន.ក.**។

**អ្នកផ្តល់សេវាសង្គម** មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជួយ **អ.ក.ន.ក.** ក្នុងការផ្តល់សេវាគាំទ្រដល់កុមារដែលបានទទួលរងនូវអំពើហិង្សា ដូចជាការឧបត្ថម្ភគាំទ្របំពេញតម្រូវការចាំបាច់បន្ទាន់ និងការផ្តល់សេវាប្រឹក្សាយោបល់ និងផ្តល់ព័ត៌មានជាក់លាក់ដល់កុមារ។ល។
- ចុះបញ្ជីកុមារផ្អែកតាមជំហាននៃការដោះស្រាយករណី ដែលទទួលរងនូវអំពើហិង្សាដែលតម្រូវឱ្យមានការជួយអន្តរាគមន៍ទាន់ពេលវេលា

- តាមដានស្ថានភាពវិវឌ្ឍន៍នៃកិច្ចអន្តរាគមន៍ជួយកុមារដែលរងគ្រោះដោយអំពើហិង្សា និងក្រុមគ្រួសាររបស់ពួកគេ
- រាយការណ៍ពីករណីអំពើហិង្សាលើកុមារទៅ **អ.ក.ន.ក.** ដើម្បីសុំអន្តរាគមន៍ឆ្លើយតប
- ចូលរួមប្រមូលទិន្នន័យកុមាររងគ្រោះ កុមារងាយរងគ្រោះ កុមារងាយនឹងប្រព្រឹត្តបទល្មើស និងកុមារទំនាស់នឹងច្បាប់ដែលត្រូវបានដោះលែងដើម្បីធ្វើផែនទីសេវាសង្គម និងធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម ដោយសហការជាមួយអាជ្ញាធរភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត
- ចូលរួមធ្វើការប៉ាន់ប្រមាណ និងការគ្រប់គ្រងហានិភ័យក្នុងសហគមន៍
- ចូលរួមប្រជុំជាមួយ **គ.ក.ន.ក.** ដើម្បីចែករំលែកព័ត៌មាន និងផ្ដល់ធាតុចូលសម្រាប់ធ្វើផែនការសកម្មភាព និងថវិកា ដើម្បីអនុវត្តកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- សហការជាមួយអ្នកអប់រំផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមសហគមន៍មូលដ្ឋាន
- សហការជាមួយផ្នែកអប់រំផ្សព្វផ្សាយ ក្រុមសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអនុវត្តវិធានការនៃកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់
- ធ្វើរបាយការណ៍ជូន **អ.ក.ន.ក.** ឱ្យបានទៀងទាត់ស្ដីពីសកម្មភាពកិច្ចការពារកុមារ
- បំពេញកិច្ចការផ្សេងៗទៀតតាមការណែនាំពី **គ.ក.ន.ក.**។

**ប្រការ៣ ៈ**

អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារស្ថិតនៅក្រោមការដឹកនាំ និងការគ្រប់គ្រងផ្ទាល់ពី **គ.ក.ន.ក.**។

**ប្រការ៤ ៈ**

បទប្បញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលឃុំ ឬសង្កាត់............. ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ៈ**

សមាជិកក្រុមប្រឹក្សាឃុំ ឬសង្កាត់.............. និងដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ..........ខែ..........ឆ្នាំ.........ស័ក ព.ស................

ធ្វើនៅ.................ថ្ងៃទី..........ខែ.............ឆ្នាំ...........

**មេឃុំ ចៅសង្កាត់**

.........

**<u>កន្លែងទទួល</u>** ៖

- សាលារាជធានី ខេត្ត.........
- សាលាក្រុង ស្រុក ខណ្ឌ.........
- ដូចប្រការ១ និងប្រការ៥
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២.ក ៖ ទម្រង់ចុះបញ្ជីករណី
## ការចុះបញ្ជីករណី

| ១. ព័ត៌មានពីកុមាររងគ្រោះ |
|---|
| ឈ្មោះកុមាររងគ្រោះ ៖ …………………………………… ភេទ ៖ ប្រុស ☐ ស្រី ☐ |
| ថ្ងៃខែឆ្នាំកំណើត ៖…………………………………………………………………………… |
| ជនជាតិ ៖……………………………………….សញ្ជាតិ ៖………………………………… |
| កម្រិតវប្បធម៌ ៖…………………………………………………………………………… |
| តើកុមាររងគ្រោះមានពិការភាពដែរឬទេ? មាន ☐ គ្មាន ☐<br>បើមានសូមបញ្ជាក់ពីប្រភេទនៃពិការភាពនោះ ៖……………………………………………… |
| ឈ្មោះឪពុក ☐ ម្ដាយ ☐ ឬអាណាព្យាបាល ☐ ៖……………………………………………<br>អាសយដ្ឋាន ៖………………………………………………………………………………<br>……………………………………………………………………………………………<br>លេខទូរស័ព្ទទំនាក់ទំនង ៖…………………………………………………………… |
| **២. ឧបទ្ទវហេតុ** |
| ប្រភេទអំពើហិង្សា (អាចគូសយកជម្រើសច្រើនជាង១)<br>ផ្លូវកាយ ☐ ផ្លូវភេទ ☐ ផ្លូវចិត្ត ☐ ការមិនអើពើ ☐ |
| ទីកន្លែងកើតហេតុ ៖………………………………………………………………………… |
| កាលបរិច្ឆេទ ៖………………………… ពេលវេលាកើតហេតុ ៖………………………………… |
| សង្ខេបអំពីហេតុការណ៍ដែលបានកើតឡើងជាក់ស្ដែង ៖……………………………………<br>……………………………………………………………………………………………<br>……………………………………………………………………………………………<br>……………………………………………………………………………………………<br>……………………………………………………………………………………………<br>…………………………………………………………………………………………… |

ថ្ងៃ..........ខែ..........ឆ្នាំ.........ស័ក ព.ស..........

.................ថ្ងៃទី......ខែ............ឆ្នាំ...........

**អ្នកពាក់ព័ន្ធដែលបានសហការ**.................... **អ.ក.ន.ក. ឬអ្នកមានសមត្ថកិច្ច**....................

**(ហត្ថលេខា និងឈ្មោះ)** **(ហត្ថលេខា និងឈ្មោះ)**

**ឧបសម្ព័ន្ធទី២.ខ ៖ បញ្ជីកត់ត្រាករណី**
**បញ្ជីកត់ត្រាករណី**

| កាលបរិច្ឆេទ | ឈ្មោះមេគ្រួសារ | ឈ្មោះកុមារ | លេខកូដកុមារ | អាយុ | ភេទ | ភូមិ (ទីកន្លែងរស់នៅ) | ប្រភេទហិង្សា | សង្ខេបករណីអំពើហិង្សា | សេវាបានទទួល/បញ្ជូន | ត្រូវការតាមដាន | ស្ថានភាពករណីអំពើហិង្សា (បើក បិទ) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃ.....................ខែ.............ឆ្នាំ.........ស័ក ព.ស...........
.................ថ្ងៃទី.........ខែ............ឆ្នាំ..........

**អ.ក.ន.ក. ឬអ្នកមានសមត្ថកិច្ច**

...........................

**ឧបសម្ព័ន្ធទី៣.ក ៖ ទម្រង់បញ្ជូនកុមារ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត .....................

ក្រុង ស្រុក ខណ្ឌ ................

រដ្ឋបាលឃុំ សង្កាត់ ..............

**ការបញ្ជូនកុមារ**

១. កាលបរិច្ឆេទបញ្ជូន ៖ .......................................................................................

២. ឈ្មោះអ្នកបញ្ជូន ៖ ............................ភេទ.....តួនាទី.....................ទូរស័ព្ទលេខ................

៣. ឈ្មោះកុមារ(ឬលេខកូដ) ៖ ........ ..................ភេទ.......អាយុ........ភូមិ............................

ឃុំ សង្កាត់........................... ក្រុង ស្រុក ខណ្ឌ........................ រាជធានី ខេត្ត.................

៤. ឈ្មោះគ្រួសារ/អាណាព្យាបាល ៖ .........................................ទូរស័ព្ទលេខ.................

៥. ឈ្មោះស្ថាប័នទទួល ៖ ................................... អាសយដ្ឋានស្ថាប័នទទួល...................

.......................................................................................................................

៦. ឈ្មោះអ្នកទទួល ៖ .................................. ភេទ.......... តួនាទី........................ទូរស័ព្ទលេខ

.......................................................................................................................

៧. មូលហេតុនៃការបញ្ជូន ៖................................................................................

.......................................................................................................................

៨. សេវាស្នើសុំ ៖ ..............................................................................................

ស្នាមមេដៃស្តាំ

| កុមារ | អ្នកដឹងឮទី១ | អ្នកដឹងឮទី២ |
|---|---|---|
| ឈ្មោះ............................ | ឈ្មោះ.................................. | ឈ្មោះ.............................. |
| | ត្រូវជាអ្វីនឹងកុមារ....................... | ត្រូវជាអ្វីនឹងកុមារ................. |

កាលបរិច្ឆេទ ៖.......................................... កាលបរិច្ឆេទ ៖.......................................

ហត្ថលេខា និងឈ្មោះអ្នកទទួល ហត្ថលេខា និងឈ្មោះអ្នកបញ្ជូន

## ឧបសម្ព័ន្ធទី៣.ខ ៖ ទម្រង់ផ្តល់ព័ត៌មានត្រឡប់ស្តីពីការបញ្ជូនកុមារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ការផ្តល់ព័ត៌មានត្រឡប់ស្តីពីការបញ្ជូនកុមារ

១. កាលបរិច្ឆេទទទួល ៖ ..........................................................................................

២. ឈ្មោះស្ថាប័នដែលផ្តល់ព័ត៌មានត្រឡប់ ៖....................................ទូរស័ព្ទលេខ...................

៣. ឈ្មោះកុមារ(ឬលេខកូដ) ៖ ............................ភេទ.......អាយុ........ភូមិ............................

ឃុំ សង្កាត់.......................... ក្រុង ស្រុក ខណ្ឌ....................... រាជធានី ខេត្ត...................

៤. ឈ្មោះស្ថាប័នដែលត្រូវផ្ញើព័ត៌មានត្រឡប់ទៅ ៖....................................................................

៨. សេវាដែលបានស្នើសុំ ៖ ..........................................................................................

៩. ឈ្មោះបុគ្គលិកដែលផ្តល់សេវា ៖....................................... រយៈពេលផ្តល់សេវា..................

១០. យោបល់របស់បុគ្គលិកដែលផ្តល់សេវា ៖ ..........................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

១១.យោបល់របស់កុមារដែលទទួលសេវា ៖ ..............................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

កាលបរិច្ឆេទ ៖

................................................

ហត្ថលេខាបុគ្គលិកនៃស្ថាប័នទទួល

**ឧបសម្ព័ន្ធទី៤ ៖ ទម្រង់ទុកដាក់កុមារ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| រូបថតកុមារ ៤ x ៦ |

**ការទុកដាក់កុមារ**

អង្គភាពប្រតិបត្តិ ៖ ..........................................................................................

អាសយដ្ឋានអង្គភាពប្រតិបត្តិ ៖ (រាជធានី ខេត្ត) ៖ ..............................................................

ក្រុង ស្រុក ខណ្ឌ ៖ ......................................... ឃុំ សង្កាត់ ៖ ...............................................

កាលបរិច្ឆេទ ៖.............................លេខកូដភូមិ ៖.....................លេខកូដកុមារ ៖......................

ខ្ញុំជាអ្នកកាន់ករណីឈ្មោះ ៖ ..........................ថ្ងៃខែឆ្នាំកំណើត ៖ ........... ភេទ ៖ ☐ ប្រុស ☐ ស្រី

បានឯកភាពទុកដាក់កុមារឈ្មោះ៖...................................ថ្ងៃខែឆ្នាំកំណើត ៖..........................

ភេទ ៖ ☐ ប្រុស ☐ ស្រី ឱ្យរស់នៅតាមជម្រើសនៃការថែទាំដូចខាងក្រោម ៖

កាលបរិច្ឆេទនៃការទុកដាក់ ៖..........................................................................................

| **ជម្រើសនៃការថែទាំ**<br>តាមលំដាប់ដូចដែលបានចែងនៅក្នុងគោលនយោបាយស្តីពីថែទាំជំនួសចំពោះកុមារ | | |
|---|---|---|
| ប្រភេទនៃការថែទាំ | ឈ្មោះអ្នកថែទាំ/ឈ្មោះកន្លែងថែទាំ | អាសយដ្ឋាន និងលេខទូរស័ព្ទ ទំនាក់ទំនង |
| ☐ គ្រួសារបង្កើត | ឈ្មោះឪពុក ៖ ..........................<br>ឈ្មោះម្តាយ ៖ .......................... | |
| ☐ សាច់ញាតិ | ឈ្មោះ ៖ ..................................<br>ឈ្មោះ ៖ .................................. | |
| ☐គ្រួសារមិនជាប់សាច់ញាតិ (គ្រួសារធម៌) | ឈ្មោះ ៖ ..................................<br>ឈ្មោះ ៖ .................................. | |
| ☐ ការថែទាំជាក្រុមក្នុងសហគមន៍ | ឈ្មោះអង្គការ ៖ ........................<br>ឈ្មោះក្រុម ៖ ........................... | |
| ☐ តាមវត្តអារាម ឬទីកន្លែងសាសនានានា | ឈ្មោះវត្ត/វិហារ ៖ .....................<br>ឈ្មោះអ្នកគ្រប់គ្រង ៖ ................ | |
| ☐ កន្លែងថែទាំកុមារ | ឈ្មោះអង្គការ ៖ ........................<br>ឈ្មោះមណ្ឌល ៖ ........................ | |

## កិច្ចព្រមព្រៀង

### កុមារ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..........................................ភេទ.........ថ្ងៃខែឆ្នាំកំណើត......................
បានយល់ព្រមមករស់នៅជាមួយ..............................និងខ្ញុំយល់ព្រមប្រឹងប្រែងឱ្យអស់ពីលទ្ធភាព គោរពតាមកម្មវិធីដែលបានធ្វើឡើងដោយបុគ្គលិកកាន់ករណី និងយល់ព្រមរួមសុខរួមទុក្ខជាមួយ................................................ ។

| ឈ្មោះ និងហត្ថលេខា/ស្នាមមេដៃ ៖ | កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) ៖ |
|---|---|
| | |

### អ្នកថែទាំ

បាទ/នាងខ្ញុំឈ្មោះ...............................................ភេទ.........ថ្ងៃខែឆ្នាំកំណើត......................
ត្រូវជា..............................របស់កុមារបានយល់ព្រមថែរក្សាបំពេញនូវតម្រូវការមូលដ្ឋានរបស់គាត់ និងប្រឹងប្រែងផ្តល់ជំនួយចាំបាច់នានា ដែលអាចធ្វើទៅបានឈរលើគោលការណ៍ធ្វើសមាហរណកម្មប្រកបដោយសុវត្ថិភាព។ ខ្ញុំបាទ/នាងខ្ញុំយល់ព្រមប្រគល់កុមារទៅអាជ្ញាធរមានសមត្ថកិច្ចវិញក្នុងករណីដែលស្ថានភាពគ្រួសារអាចប៉ះពាល់ដល់សុខុមាលភាព និងសុវត្ថិភាពកុមារ។

កាលបរិច្ឆេទ ៖ ..............................................................................................................

ឈ្មោះ និងហត្ថលេខា/ស្នាមមេដៃរបស់អ្នកថែទាំ (ឪពុក/ម្តាយ/អាណាព្យាបាល) ៖

### អ្នកកាន់ករណី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................................. ភេទ......... អាយុ............. ជាអ្នកកាន់ករណីបានឯកភាពទុកដាក់កុមារជាមួយ................................................................................ ។
ខ្ញុំនឹងចុះសួរសុខទុក្ខកុមាររូបនេះ និងគ្រួសារយ៉ាងទៀងទាត់ និងតាមការចាំបាច់។ ខ្ញុំនឹងខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីជួយដោះស្រាយការលំបាកនានាដែលអាចកើតឡើងចំពោះកុមារ និងផ្តល់ជំនួយគាំទ្រនានាដែលចាំបាច់ ដើម្បីឱ្យការទុកដាក់បានជោគជ័យ និងប្រកបដោយសុវត្ថិភាព។

កាលបរិច្ឆេទ ៖ ..............................................................................................................

| ហត្ថលេខា/ស្នាមមេដៃអ្នកកាន់ករណី ៖ | ហត្ថលេខា និងត្រា មេឃុំ ចៅសង្កាត់ |
|---|---|
| ឈ្មោះ ៖ ........................................................ | ឈ្មោះ ៖ ................................................... |
| តួនាទី ៖ ........................................................ | |
| ឈ្មោះអង្គការ/ស្ថាប័ន ៖ ........................................................ | |

## ឧបសម្ព័ន្ធទី៥ ៖ បញ្ជីអ្នកពាក់ព័ន្ធកិច្ចការពារកុមារ

### បញ្ជីអ្នកពាក់ព័ន្ធកិច្ចការពារកុមារ

| ល.រ | ឈ្មោះ | តួនាទី | ទូរស័ព្ទ | ប្រព័ន្ធទំនាក់ទំនងផ្សេងទៀត |
|---|---|---|---|---|
| **១. សមាជិក គ.ក.ន.ក.** | | | | |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |
| ១០ | | | | |
| ១១ | | | | |
| ១២ | | | | |
| **២. អ្នកស្ម័គ្រចិត្តទ្រទ្រង់កិច្ចការពារកុមារឃុំ សង្កាត់** | | | | |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| **៣. ក្រុមសហគមន៍មូលដ្ឋាន** | | | | |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |

| ល.រ | ឈ្មោះ | តួនាទី | ទូរស័ព្ទ | ប្រព័ន្ធទំនាក់ទំនងផ្សេងទៀត |
|---|---|---|---|---|
| **៤. អាជ្ញាធរមានសមត្ថកិច្ច** | | | | |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |
| **៥. អង្គការសង្គមស៊ីវិល** | | | | |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |
| **៦. អ្នកពាក់ព័ន្ធផ្សេងៗទៀត** | | | | |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |

បោះពុម្ពដោយ

World Vision

Save the Children

PLAN INTERNATIONAL

ChildFund Cambodia

educo Member of ChildFund Alliance